# ផែនការសកម្មភាពអនុតំបន់លើកទី ៣

# នៃកិច្ចសម្របសម្រួលគំនិតផ្តួចផ្តើមថ្នាក់រដ្ឋមន្ត្រីនៅមហាអនុតំបន់មេគង្គប្រឆាំង

# នឹងការជួញដូរមនុស្ស

# (COMMIT SPA III 2011-2013)

## សេចក្តីព្រាងសម្រាប់ការពិភាក្សា នៅក្នុងកិច្ចប្រជុំ

## PRE-COMMIT SOM 8 / IMM 3

ខែ មករា ឆ្នាំ ២០១០

ក្រុងបាងកក ប្រទេសថៃ

នៅមុនកិច្ចប្រជុំ

COMMIT SOM 8 / IMM 3

# មាតិកា


**និដ្ឋភាពរួមនៃដំណើរការ COMMIT និង COMMIT SPA លើកទី៣**..........៣

១. សាវតារ: ការវិវត្តនៃដំណើរការ COMMIT..........៤

២. អនុស្សរណៈយោគយល់របស់ COMMIT..........៥

៣. ផែនការសកម្មភាពអនុតំបន់ទី១របស់ COMMIT (២០០៥ -២០០៧)..........៥

៤. ផែនការសកម្មភាពអនុតំបន់ទី២របស់ COMMIT (២០០៨-២០១០)..........៦

៥. ផែនការសកម្មភាពអនុតំបន់ទី៣របស់ COMMIT (២០១១-២០១៣)..........៦

៦. ការវិវត្តនៃផែនការសកម្មភាពថ្នាក់អនុតំបន់របស់ COMMIT..........៨

៧. តួនាទីសំខាន់ៗនិងទំនាក់ទំនងនៅក្នុងដំណើរការរបស់ COMMIT ដែលគាំទ្រដល់និរន្តរភាពរបស់ COMMIT..........៩

៨. គោលការណ៍ណែនាំនៃដំណើរការរបស់ COMMIT**Error! Bookmark not defined.**...១០

**ផែនការសកម្មអនុតំបន់លើកទី៣** (COMMIT SPA III (2011-2013)

ផ្នែក 1. គោលនយោបាយនិងកិច្ចសហប្រតិបត្តិការ..........១១

ផ្នែក 2. ក្របខ័ណ្ឌច្បាប់ ការអនុវត្តច្បាប់ និងយុត្តិធម៌..........១៦

ផ្នែក 3. កិច្ចការពារ ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្ម..........២២

ផ្នែក 4. វិធានការបង្ការទប់ស្កាត់ និងការកាត់បន្ថយភាពងាយរងគ្រោះ..........២៩

ផ្នែក 5. ប្រព័ន្ធពិនិត្យតាមដាន វាយតម្លៃ និងប្រមូលចងក្រងទិន្នន័យសម្រាប់ការងារប្រឆាំងនឹងការជួញដូរមនុស្ស......៣៥

តារាងសង្ខេបចំណុចដៅនិងសកម្មភាពទាំងអស់របស់ COMMIT SPA III..........៣៩


## ឧបសម្ព័ន្ធ


ឧបសម្ព័ន្ធ ក: អនុស្សរណៈនៃការយោគយល់ COMMIT (2004)..........៥១

ឧបសម្ព័ន្ធ ខ: សេចក្តីថ្លែងការណ៍រួមរបស់ COMMIT (2007)..........៦០

# ទិដ្ឋភាពរួម

## នៃដំណើរការ COMMIT និងផែនការសកម្មអនុតំបន់ទី៣ របស់ខមមីត

## 2011-2013

(COMMIT SPA III, 2011-2013)

## ១. សារតារៈ ការវិវត្តនៃដំណើរការ COMMIT

កិច្ចសម្របសម្រួលគំនិតផ្តួចផ្តើមថ្នាក់រដ្ឋមន្ត្រីមហាអនុតំបន់មេគង្គប្រឆាំងការជួញដូរមនុស្ស (COMMIT) តំណាងឱ្យ ដំណើរការដែលនាំមុខដោយរដ្ឋាភិបាលនៃប្រទេសទាំងប្រាំមួយនៅក្នុងមហាអនុតំបន់មេគង្គ (កម្ពុជា ចិន ឡាវ ភូមា ថៃ និង វៀតណាម) នៅក្នុងសម្ព័ន្ធភាពផ្លូវការមួយ ដើម្បីប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ។ ដំណើរការ COMMIT ត្រូវបានផ្តួចផ្តើម ឡើង ដើម្បីបង្កើតប្រព័ន្ធសហ ប្រតិបត្តិការ និងសហការមួយប្រកបដោយប្រសិទ្ធិភាព និងមាននិរន្តរភាពសម្រាប់ប្រយុទ្ធប្រឆាំងការ ជួញដូរមនុស្ស ។ សកម្មភាព ប្រឆាំងការជួញដូរមនុស្ស ដែលត្រូវបានអនុវត្តក្រោមការគាំទ្រពី COMMIT ត្រូវបានបង្កើតឡើង និង អនុវត្តតាមរយៈភាពជាដៃគូបែបថ្មីមួយរវាងរដ្ឋមន្ត្រីនៃរដ្ឋាភិបាលជាច្រើន នៅក្នុងមហាអនុតំបន់មេគង្គ និងដៃគូអភិវឌ្ឍន៍នានា ។ យុទ្ធវិធីនេះមានលក្ខណៈជាការពិគ្រោះយោបល់ និងសហការ ដែលពាក់ព័ន្ធជាមួយសង្គមស៊ីវិល ទីភ្នាក់ងារគាំពារជនរងគ្រោះ អង្គការអន្តរជាតិ ជនរងគ្រោះពីការជួញដូរ ដែលរួមទាំងកុមារ និងយុវជនផងដែរ ។

ដំណើរការ COMMIT មានគោលបំណងដូចតទៅ :

- ជម្រុញ និងពង្រឹងប្រព័ន្ធ និងការចាត់ចែងនានានៃកិច្ចសហប្រតិបត្តិការរវាងប្រទេស និងនៅថ្នាក់តំបន់ ដើម្បីប្រឆាំងការជួញដូរមនុស្ស ។
- បង្កើតវិធានការឆ្លើយតបគ្រប់ជ្រុងជ្រោយថ្នាក់តំបន់ ដែលគ្របដណ្តប់គ្រប់ទិដ្ឋភាពនៃការជួញដូរមនុស្ស និងការធានាថាកង្វល់នៃជនរងគ្រោះ ស្ថិតនៅជាស្នូលនៃអន្តរាគមន៍ទាំងអស់ ។
- កំណត់ និងអនុម័តយកគំរូនានាដែលជោគជ័យ នៅក្នុងប្រទេសមួយ ទៅប្រទេសមួយផ្សេងទៀតឱ្យបានសមស្រប
- ពង្រឹងសមត្ថភាពជាតិដើម្បីដោះស្រាយបញ្ហាជួញដូរមនុស្ស ដើម្បីសម្រួលឱ្យមានការចូលរួមនៃប្រទេសនីមួយៗនៅថ្នាក់តំបន់ ដោយកសាងភាពខ្លាំងដែលមានស្រាប់នៅក្នុងប្រទេសនីមួយៗ ។

## អនុស្សរណៈនៃការយោគយល់ក្នុងក្របខ័ណ្ឌ COMMIT

នៅក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីលើកទីមួយ (IMM 1) កាលពីខែតុលា ឆ្នាំ ២០០៤ អនុស្សរណៈនៃការយោគយល់មួយ (MOU) ក្នុងក្របខ័ណ្ឌ COMMIT ត្រូវបានធ្វើឡើង ដោយមានការចុះហត្ថលេខាពីរដ្ឋមន្ត្រីនៃប្រទេសទាំងប្រាំមួយនៅក្នុងមហាអនុតំបន់មេគង្គ (យោងឧបសម្ព័ន្ធ ក) ។ អនុស្សរណៈនេះចែកជាប្រាំផ្នែក ដែលមានសរុប ៣១ មាត្រា ។ ផ្នែកទី ៥ នៃអនុស្សារណៈនេះ បានបង្កើតជា ហេដ្ឋារចនាសម្ព័ន្ធ និងនីតិវិធីសម្រាប់ដំណើរការ COMMIT ដែលរួមមាន :

- **មាត្រា២៨** : បង្កើតផែនការសកម្មភាពថ្នាក់អនុតំបន់ដំបូងមួយសម្រាប់ឆ្នាំ ២០០៥-២០០៧ ក្នុងបំណងប្រឆាំងការជួញដូរមនុស្ស និងអនុវត្តគ្រប់កិច្ចប្រឹងប្រែង ដើម្បីសម្រេចផែនការនេះឱ្យបានពេញលេញ
- **មាត្រា៣១** : ពិនិត្យមើលការអនុវត្តផែនការសកម្មភាពនេះ និងអនុម័តផែនការសកម្មភាពថ្នាក់អនុតំបន់ថ្មីមួយ តាមរយៈកិច្ចប្រជុំថ្នាក់អនុតំបន់មេគង្គ នៅចុងឆ្នាំ ២០០៧
- **មាត្រា៣២**: បង្កើតក្រុមការងារថ្នាក់ជាតិ ដើម្បីសហការជាមួយលេខាធិការដ្ឋាន COMMIT (គម្រោងអន្តរទីភ្នាក់ងារសហប្រជាជាតិ ប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៅក្នុងមហាអនុតំបន់មេគង្គ ហៅកាត់ថា UNIAP) និងដៃគូដទៃទៀត

**មាត្រា ៣៣ :** អញ្ជើញទីភ្នាក់ងារផ្តល់មូលនិធិនៃរដ្ឋាភិបាល ក៏ដូចជា អង្គការសហប្រជាជាតិ និងអង្គការអន្តររដ្ឋាភិបាល និង អង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធ និងវិស័យឯកជន ដើម្បីឱ្យផ្តល់ជំនួយហិរញ្ញវត្ថុ សម្ភារ និងបច្ចេកទេសសម្រាប់ គាំទ្រដល់ ប្រទេសនៅក្នុងមហាអនុតំបន់មេគង្គ នៅក្នុងកិច្ចប្រឹងប្រែងរបស់ខ្លួនប្រឆាំងការជួញដូរមនុស្ស ដែលរួមទាំង ការអនុវត្តអនុស្សរណៈ នេះ និងផែនការសកម្មភាពនៅពេលខាងមុខ ។

មាត្រាពាក់ព័ន្ធដទៃទៀត នៅក្នុងសេចក្តីថ្លែងការណ៍នាំមុខនៃអនុស្សរណៈ COMMIT សង្កត់ធ្ងន់លើការប្តេជ្ញាដាច់ខាត ពី សំណាក់រដ្ឋាភិបាលនៃប្រទេសទាំងប្រាំមួយ ដើម្បីកាត់បន្ថយប្រកបដោយការគិតគូរជាមុននូវនិទណ្ឌភាពសម្រាប់អ្នកជួញដូរមនុស្ស ការពារសិទ្ធិរបស់ជនត្រូវគេជួញដូរ និងធ្វើឱ្យរដ្ឋាភិបាលបង្ហាញពីការប្តេជ្ញាខាងធនធានមនុស្ស និងហិរញ្ញវត្ថុដល់កិច្ចប្រឹងប្រែងប្រឆាំង ការជួញដូរមនុស្ស :

- ***មានកង្វល់យ៉ាងជ្រាលជ្រៅ*** អំពីការឈឺចាប់ដែលបង្កដោយការជួញដូរមនុស្ស នៅក្នុងមហាអនុតំបន់មេគង្គ និងពីរដ្ឋនៅ ក្នុងមហាអនុតំបន់មេគង្គ ទៅតំបន់ដទៃទៀតនៅលើពិភពលោក ។
- ***អះអាងថា*** គឺជាការមិនអាចទទួលយកបានទាល់តែសោះ ដែលមនុស្សត្រូវបានគេជួញដូរ ទិញ លក់ ចាប់ជម្រិត បង្ខាំង និង ឃុំទុកនៅក្នុងស្ថានភាពកេងប្រវ័ញ្ច ដែលជាការបំបាត់សិទ្ធិសំខាន់បំផុត និងដែលមិនអាចកាត់ផ្តាច់បានរបស់អ្នកទាំងនោះ
- ***ទទួលស្គាល់***ពីភាពចាំបាច់សម្រាប់ពង្រឹងការឆ្លើយតបប្រកបដោយយុត្តិធម៌ទៅនឹងអំពើព្រហ្មទណ្ឌ ដើម្បីផ្តល់យុត្តិធម៌ សម្រាប់ជនរងគ្រោះនានាពីការជួញដូរ និងបញ្ចប់និទណ្ឌភាពសម្រាប់អ្នកជួញដូរ ដែលទទួលផលចំណេញពីឧក្រិដ្ឋកម្មនេះ
- ***ទទួលស្គាល់***ពីសារៈសំខាន់នៃទណ្ឌកម្មយ៉ាងមានប្រសិទ្ធិភាព និងតាមកម្រិតឧក្រិដ្ឋកម្មមកលើអ្នកជួញដូរ ដែលរួមទាំង មាត្រាដែលចែងអំពីការបង្កក និងរឹបអូសធនធានរបស់អ្នកទាំងនោះ និងដើម្បីយកផលចំណូលទាំងនេះប្រើប្រាស់ជា ប្រយោជន៍របស់ជនរងគ្រោះនៃការជួញដូរ ។
- ***ទទួលស្គាល់ថា*** រដ្ឋាភិបាលនៃប្រទេសនីមួយៗ ចាត់វិធានការរៀងៗខ្លួន និងតាមរយៈជំនួយអន្តរជាតិ និងសហប្រតិបត្តិការ ក្នុងបំណងបង្កើនធនធានដែលខ្លួនមាន ដើម្បីសម្រេចបានជាបន្តបន្ទាប់នូវការប្តេជ្ញាពេញលេញ ដែលបានទទួលស្គាល់នៅ ក្នុងអនុស្សរណៈនេះ តាមគ្រប់មធ្យោបាយសមស្រប ។
- ***មានចេតនា***ឱ្យអនុស្សរណៈនេះ ឆ្លុះបញ្ចាំងពេញលេញ អំពីឆន្ទៈនយោបាយជាប់ជាបន្តនៃរដ្ឋាភិបាលរបស់យើង ក្នុងការធ្វើ សហប្រតិបត្តិការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និង
- ***អំពាវនាវ***ដល់ប្រទេសទាំងអស់នៅក្រៅមហាអនុតំបន់មេគង្គឱ្យចូលរួមជាមួយប្រទេសយើង ក្នុងការប្រយុទ្ធប្រឆាំងការ ជួញដូរមនុស្ស ។

## ផែនការសកម្មភាពអនុតំបន់ទី១របស់ COMMIT

### (COMMIT SPA I, 2005-2007)

ក្នុងគោលបំណងបម្លែងអនុស្សរណៈនេះទៅជាសកម្មភាព កិច្ចប្រជុំ មន្ត្រីជាន់ខ្ពស់ ប្រចាំឆ្នាំជាបន្តបន្ទាប់ (SOMs) ក៏ដូច ជាការពិគ្រោះយោបល់នៅថ្នាក់អនុតំបន់ និងថ្នាក់ជាតិ បាននាំឱ្យរដ្ឋាភិបាលទាំងប្រាំមួយអនុម័តផែនការសកម្មភាពថ្នាក់អនុតំបន់ជា លើកដំបូងនៅក្នុងឆ្នាំ ២០០៥ (COMMIT SPA I, 2005-2007) ដែលរួមបញ្ចូលគោលគំនិតសំណើគម្រោង (PPCs) ចំនួន ដប់ពីរ ។ ការកែតម្រូវលើ SPA I ដែលបានធ្វើឡើងនៅក្នុងកិច្ចប្រជុំកសាងផែនការយុទ្ធសាស្ត្រ នាក្រុងវៀងច័ន្ទ ប្រទេសឡាវ ក្នុងខែ

សីហា ឆ្នាំ ២០០៦ បានកាត់បន្ថយគោលគំនិតសំណើគម្រោងឱ្យនៅសល់ចំនួនដប់ ដែលរួមទាំង SPA I (2005-2007) ដូចមាន បង្ហាញនៅក្នុងតារាងទំព័រលេខ ៨។

## ផែនការសកម្មភាពអនុតំបន់ទី២របស់ COMMIT

### (COMMIT SPA II, 2008-2010)

មាត្រា ៣១ នៃអនុស្សារណៈ COMMIT ចែងដូចតទៅ :

*"ពិនិត្យមើលការអនុវត្តផែនការសកម្មភាព និងការអនុម័តលើផែនការសកម្មភាព ថ្នាក់អនុតំបន់ ថ្មីមួយ តាមរយៈកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីនៃប្រទេសនៅក្នុងមហាអនុតំបន់មេគង្គ នៅចុងឆ្នាំ ២០០៧ "។*

ក្នុងន័យនេះ មាត្រា ៣១ នៃអនុស្សរណៈ COMMIT បានចែងថា អាយុកាលនៃ COMMIT SPA នឹងត្រូវបន្តរហូតដល់ខែ ធ្នូ ឆ្នាំ ២០០៧ ដែលទាមទារឱ្យមានផែនការសកម្មភាពថ្នាក់អនុតំបន់លើកទីពីរ ដើម្បីបន្តការប្តេជ្ញា និងសកម្មភាពដែលបានចាប់ផ្តើមដោយអនុស្សារណៈ COMMIT និង COMMIT SPA (2005-2007). នៅក្រោយការពិគ្រោះយោបល់ជាបន្តបន្ទាប់រវាងរដ្ឋាភិបាល និងរដ្ឋាភិបាល-អង្គការមិនមែនរដ្ឋាភិបាល និងដោយមានការគាំទ្រពីលេខាធិការដ្ឋាន COMMIT, សេចក្តីព្រាង COMMIT SPA II (2008-2010) ត្រូវបានរៀបរៀងឡើងនៅចុងឆ្នាំ ២០០៦ និងបានការឯកភាពពីរដ្ឋមន្ត្រីនៃរដ្ឋាភិបាលក្នុងប្រទេសទាំងប្រាំមួយ នៅក្នុង COMMIT នៅក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីលើកទីពីរ (IMM 2) កាលពីខែធ្នូ ឆ្នាំ 2007 ដោយមានកំណែលម្អដូចខាងក្រោមនេះ បន្ថែមលើ COMMIT SPA I:

- នៅក្នុង SPA I សកម្មភាពកំណត់អត្តសញ្ញាណកម្មជនរងគ្រោះ បានធ្វើឡើងដាច់ដោយឡែកពីសកម្មភាពផ្សេងទៀតនៃកិច្ចការពារជនរងគ្រោះ ប៉ុន្តែបានរួមបញ្ចូលគ្នានៅក្រោមប្រធានបទតែមួយនៃកិច្ចការពារជនរងគ្រោះ នៅក្នុង SPA II, ស្របជាមួយខ្លឹមសារពីដំបូងនៃអនុស្សារណៈ COMMIT ។
- នៅក្នុង SPA I សកម្មភាពនាំយកមកកាត់ទោស និងការចាប់ខ្លួនជនល្មើស ស្ថិតនៅដាច់ចេញពីសកម្មភាពផ្សេងទៀតខាងផ្នែកយុត្តិធមិព្រហ្មទណ្ឌ ប៉ុន្តែត្រូវបានរួមបញ្ចូលនៅក្រោមប្រធានបទតែមួយនៃយុត្តិធមិព្រហ្មទណ្ឌ នៅក្នុង SPA II, ដោយមានចំណងជើង និងវិសាលភាព ស្របជាមួយខ្លឹមសារពីដំបូងនៃអនុស្សារណៈ COMMIT ។
- សកម្មភាពទប់ស្កាត់ការជួញដូរមនុស្សនៅក្រោម SPA I មានចែងតែអំពីការកេងប្រវ័ញ្ចនៃឈ្មួញកណ្តាល ដែលត្រូវបានពង្រីកនៅក្នុង SPA II ដើម្បីដាក់បញ្ចូលសកម្មភាពដទៃទៀតនៃការទប់ស្កាត់អំពើជួញដូរ ដោយមានចំណងជើង និងវិសាលភាពស្របគ្នាជាមួយអនុស្សរណៈ COMMIT ។
- ចំណងជើងសម្រាប់ PPC 1 និង PPC 3 នៃ SPA II ត្រូវបានធ្វើបច្ចុប្បន្នភាពឱ្យសមស្រប ។
- ប្រការសំខាន់គឺ ក្របខ័ណ្ឌតាមដាន និងវាយតម្លៃ ត្រូវបានដាក់បញ្ចូលទៅក្នុង COMMIT SPA II, ដែលពុំមាននៅក្នុង COMMIT SPA I ។ ផ្នែកនីមួយៗនៃសកម្មភាព ផ្សំដោយចំណុចដៅ និងកាលវិភាគ សម្រាប់គោលដៅសំខាន់ៗ ដែលបានឯកភាពដោយរដ្ឋាភិបាលនៃប្រទេសទាំងប្រាំមួយនៅក្នុង COMMIT ហើយលេខាធិការដ្ឋាន COMMIT បានរៀបចំរបាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍តាមដាន ដោយប្រើប្រាស់ក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃនេះ ។

## ផែនការសកម្មភាពអនុតំបន់ទី៣ របស់ COMMIT

### (COMMIT SPA III, 2011-2013)

COMMIT SPA III ត្រូវបានរៀបរៀងជាសេចក្តីព្រាង ពិភាក្សា និងឯកភាពនៅចុងឆ្នាំ 2010 ដោយផ្តោតលើ :

- តើការប្តេជ្ញានៅក្នុងអនុស្សរណៈដើមនៃ COMMIT បានឆ្លុះបញ្ចាំងបែបណានៅក្នុង COMMIT SPAs មកទល់ពេលនេះ និងការកំណត់ចំណុចខ្វះចន្លោះ ដែលត្រូវដោះស្រាយនៅក្នុង COMMIT SPA III
- តើការប្តេជ្ញានៅក្នុងអនុស្សរណៈដើមនៃ COMMIT ត្រូវបានរដ្ឋាភិបាលនៅក្នុង COMMIT បានយកមកអនុវត្តបែបណាមកទល់ពេលនេះ និង ការកំណត់ចំណុចខ្វះចន្លោះ ដែលត្រូវចាត់ទុកថាជាអាទិភាពខ្ពស់ នៅក្នុងអំឡុងនៃការអនុវត្ត COMMIT SPA III;
- សកម្មភាពដែលបានបញ្ចប់ ធៀបនឹងសកម្មភាពដែលនៅពុំទាន់បញ្ចប់ នៅក្រោម COMMIT SPA I និង II និងភាពសមស្រប នៃការរំកិលសកម្មភាពខ្លះៗដែលនៅពុំទាន់បានបញ្ចប់ដើម្បីបញ្ចូលទៅក្នុង COMMIT SPA III
- ការកែប្រែរចនាសម្ព័ន្ធនៅក្នុង COMMIT SPA III, ជាមួយសកម្មភាពនានាដែលមានចែងមិនសូវក្បោះក្បាយ ក្នុងការទទួលស្គាល់ភាពបត់បែនបាន ដែលចាំបាច់សម្រាប់ប្រទេសនីមួយៗ ក្នុងការអនុវត្តសកម្មភាពនានាតាមរបៀបខុសគ្នា និង
- ការពិចារណាផងដែរអំពីកិច្ចផ្តួចផ្តើមថ្មីៗដើម្បីប្រឆាំងការជួញដូរមនុស្ស ដោយផ្អែកលើមេរៀនដែលទទួលបាន នៅក្នុងតំបន់មេគង្គ និងតំបន់ដទៃទៀតនៅអាស៊ី និងនៅទូទាំងពិភពលោក។

រចនាសម្ព័ន្ធនៃ COMMIT SPA III (2011-2013) មានលក្ខណៈស្របគ្នាជាមួយអនុស្សរណៈដើមដំបូងនៃ COMMIT ដែលផ្សំដោយផ្នែកចម្បងៗចំនួនប្រាំ ដែលមាននៅក្នុង COMMIT SPA III។ ពាក្យដែលប្រើប្រាស់ ដើម្បីអធិប្បាយផ្នែកដទៃទៀតនៅក្នុង COMMIT SPA I និង COMMIT SPA II – ‘PPC’, ឬ "គោលគំនិតសំណើគម្រោង" – ត្រូវបានបោះបង់ចោល និងជំនួសដោយពាក្យ "ផ្នែក" នៅក្នុង COMMIT SPA III។ ទាក់ទងនឹងចំណុចនេះដែរ ចំណុចដៅ និងកាលវិភាគនៃក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃរបស់ COMMIT ត្រូវបានបង្ហាញឱ្យឃើញកាន់តែលេចធ្លោ ព្រមទាំងបង្វែរការយកចិត្តទុកដាក់កាន់តែខ្លាំងទៅរកការប៉ងប្រាថ្នា និងផ្តោតលើលទ្ធផលនៃដំណើរការ COMMIT។ លើសពីនេះ ផ្នែកនៃការបណ្តុះបណ្តាល និងការកសាងសមត្ថភាព ត្រូវបានលុបបំបាត់ ដោយសកម្មភាពបណ្តុះបណ្តាលភាគច្រើន កំពុងត្រូវបានដាក់ទៅក្នុងផ្នែកនីមួយៗដើម្បីគូសបញ្ជាក់អំពីភាពចាំបាច់ឱ្យមានជំនាញឯកទេសនិងការកសាងសមត្ថភាពកាន់តែច្រើនឡើង។ នៅក្នុងផ្នែកនីមួយៗ សកម្មភាពចម្បងជាច្រើនដែលបានព្រមព្រៀងជាមួយនឹងរដ្ឋាភិបាល ត្រូវបានសម្គាល់ដោយសញ្ញា ‘★’ និងរាល់រដ្ឋាភិបាលទាំងអស់ត្រូវបានលើកទឹកចិត្តដើម្បីសំរេចសកម្មភាពទាំងនោះ ក្នុងអំឡុងពេលនៃ COMMIT SPA III។ ចំណែកឯសកម្មភាពដទៃទៀតទាំងអស់ត្រូវបានរដ្ឋាភិបាល COMMIT យល់ព្រមលើកយកមកបង្ហាញ ដោយអាស្រ័យទៅនឹងតំរូវការដែលមានតែមួយនៅពេលដែលមានស្ថានភាពសមរម្យ ស្របទៅនឹងអាទិភាពផ្សេងៗរបស់ប្រទេសនីមួយៗ។

ការវិវត្តនៃផែនការសកម្មភាពថ្នាក់អនុតំបន់ COMMIT មានបង្ហាញជូននៅក្នុងតារាងនេះ : ការវិវត្តនៃផែនការសកម្មភាពថ្នាក់អនុតំបន់ COMMIT (ទំព័រលេខ ៨)។

## ២. ការវិវត្តនៃផែនការសកម្មភាពអនុតំបន់របស់ COMMIT(SPA I 2005-2007, SPA II 2008-2010, និង SPA III 2011-2013)

| PPCs នៃ COMMIT SPA I (2005) ដើមដំបូង | COMMIT SPA I PPCs ដែលបានកែ សម្រួល ក្រោយកិច្ចប្រជុំយុទ្ធសាស្ត្រក្រុងរៀងច័ន្ទ(2006) | COMMIT SPA II PPCs (2008-2010) | គោលដៅនៃ COMMIT SPA III (2011-2013) | ផ្នែកដំបូងនានានៃ COMMIT MOU (ចុះហត្ថលេខាឆ្នាំ 2004) |
|---|---|---|---|---|
| **PPC 1 –** កម្មវិធីបណ្តុះបណ្តាលថ្នាក់តំបន់ | **PPC 1 –** កម្មវិធីបណ្តុះបណ្តាលថ្នាក់តំបន់ | **PPC 1 –** ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព | ផ្នែក **1.** គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ | **I.** គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ |
| **PPC 2 –** ការកំណត់អត្តសញ្ញាណជនរងគ្រោះនិងការ ចាប់ខ្លួនជនល្មើស | **PPC 2 –** ការកំណត់អត្តសញ្ញាណជនរងគ្រោះ និង ការចាប់ខ្លួនជនល្មើស | | | |
| **PPC 3 –** ផែនការសកម្មភាពជាតិ | **PPC 3 –** ផែនការសកម្មភាពជាតិ | **PPC 2 –** ផែនការសកម្មភាពជាតិ | | |
| **PPC 4 –** ភាពជាដៃគូពហុវិស័យ និងទ្វេភាគី | **PPC 4 –** ភាពជាដៃគូពហុវិស័យ និងទ្វេភាគី | **PPC 3 –** ភាពជាដៃគូពហុនិងទ្វេភាគី | | |
| **PPC 5 –** ក្របខ័ណ្ឌច្បាប់ | **PPC 5 –** ក្របខ័ណ្ឌច្បាប់ និងជំនួយផ្នែកច្បាប់ដល់គ្នាទៅវិញទៅមក | **PPC 4 –** ក្របខ័ណ្ឌច្បាប់, ពង្រឹងការអនុវត្តច្បាប់ និងយុត្តិធម៌ | ផ្នែក **2.** ក្របខ័ណ្ឌច្បាប់, ពង្រឹងការ អនុវត្តច្បាប់ និងយុត្តិធម៌ | **II.** ក្របខ័ណ្ឌច្បាប់, ពង្រឹងការអនុវត្តច្បាប់ និងយុត្តិធម៌ |
| **PPC 6 –** ការធ្វើមាតុភូមិនិវត្តន៍ដោយសុវត្ថិភាព និងទាន់ពេលវេលា | **PPC 6 –** ការធ្វើមាតុភូមិនិវត្តន៍ដោយសុវត្ថិភាព និងទាន់ពេលវេលា | **PPC 5 –** ការកំណត់អត្តសញ្ញាណជនរងគ្រោះ កិច្ចការពារ ស្តានិតិសម្បទា និង សមាហរណកម្មឡើងវិញ | ផ្នែក **3.** ការពារ ស្តានិតិសម្បទាន និងសមាហរណកម្មឡើងវិញ | **III.** ការពារ ស្តានិតិសម្បទាន និងសមាហរណកម្មឡើងវិញ |
| **PPC 7 –** ការគាំទ្រ និងធ្វើសមាហរណកម្មឡើងវិញ នៅក្រោយគ្រោះថ្នាក់ | **PPC 7 –** ការគាំទ្រនៅក្រោយគ្រោះថ្នាក់ ដែលរួមទាំង ខាងសង្គម និងសេដ្ឋកិច្ច ដល់ជនរងគ្រោះ និងធ្វើសមាហរណកម្មឡើងវិញ | | | |
| **PPC 8 –** បត្យាប័ន និងជំនួយខាងផ្នែកច្បាប់ទៅវិញទៅមក | **PPC 8 –** ដោះស្រាយការបែបកេងប្រវ័ញ្ច នៃឈ្មួញកណ្តាល | **PPC 6 –** វិធានការទប់ស្កាត់ | ផ្នែក **4.** វិធានការទប់ស្កាត់ និងកាត់បន្ថយភាពងាយរងគ្រោះ | **IV.** វិធានការទប់ស្កាត់ |
| **PPC 9 –** ដោះស្រាយការកេងប្រវ័ញ្ច នៃឈ្មួញកណ្តាល | **PPC 9 –** សហប្រតិបត្តិការជាមួយវិស័យទេសចរណ៍ | **PPC 7 –** សហប្រតិបត្តិការជាមួយវិស័យទេសចរណ៍ | | |
| **PPC 10 –** ការគាំទ្រខាងសេដ្ឋកិច្ច និងសង្គមដល់ជនរងគ្រោះ | **PPC 10 –** ការគ្រប់គ្រង : សម្របសម្រួល ការតាមដាន និងវាយតម្លៃ | **PPC 8 –** ការគ្រប់គ្រង : សម្របសម្រួល តាមដាន និងវាយតម្លៃ | ផ្នែក **5.** ប្រព័ន្ធពិនិត្យតាមដាន វាយតំលៃ និងប្រមូលចងក្រងទិន្នន័យសម្រាប់ការងារប្រឆាំងការជួញដូរមនុស្ស | **V.** ការអនុវត្ត ការតាមដាន និងវាយតម្លៃ |
| **PPC 11 –** សហប្រតិបត្តិការជាមួយវិស័យទេសចរណ៍ | | | | |
| **PPC 12 –** ការគ្រប់គ្រង : សម្របសម្រួល ការពិនិត្យតាមដាន និងវាយតម្លៃ | | | | |

## តួនាទីសំខាន់ៗនិងទំនាក់ទំនងនៅក្នុងដំណើរការCOMMIT ដែលគាំទ្រដល់និរន្តរភាពរបស់COMMIT

ចាប់តាំងពីដើមដំបូង COMMIT ដែលជាដំណើរការមួយ បានផ្សារភ្ជាប់រដ្ឋាភិបាល អង្គការសហប្រជាជាតិ ម្ចាស់ជំនួយ សង្គមស៊ីវិល និងដៃគូនានាក្នុងវិស័យឯកជន មករួមជាមួយគ្នា ដើម្បីទាញយកផលចំណេញពីភាពខ្លាំងនៃអង្គការនីមួយៗ ។ ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបអំពីរបៀបរួមបញ្ចូលតួនាទី និងការទទួលខុសត្រូវរបស់ដៃគូនីមួយៗ ។ UNIAP ដែលជាលេខាធិការដ្ឋាននៃដំណើរការ COMMIT ជាអ្នកផ្តល់នូវការគាំទ្រលើការកៀងគរឱ្យមានការសម្របសម្រួល ការតាមដាន កម្មវិធី បច្ចេកទេស រដ្ឋបាល និងធនធានសម្រាប់ដំណើរការ COMMIT បន្ថែមពីលើវិភាគទានដទៃទៀត ក្នុងនាមជាអង្គភាពមួយរបស់អង្គការសហប្រជាជាតិ ។



## គោលការណ៍ណែនាំរបស់ដំណើរការ COMMIT

នៅក្នុងឆ្នាំ ២០១០ ខែមិថុនា រដ្ឋាភិបាល COMMIT បានយល់ព្រមរៀបចំ គោលការណ៍ណែនាំសំរាប់ការ អនុវត្តនៃសកម្មភាព ប្រចាំថ្ងៃ ឱ្យបានកាន់តែច្រើន រួមទាំងការសម្របសម្រួលដែលឋិតនៅក្រោមដំណើរការរបស់ COMMIT ។ គោលការណ៍ណែនាំមានដូច ខាងក្រោម ៖

| | |
|---|---|
| ១ | គាំទ្រភាពជាម្ចាស់ និងការអនុវត្តរបស់រដ្ឋាភិបាល |
| ២ | សហប្រត្តិបត្តិការលើគ្រប់កម្រិត ដោយធ្វើឱ្យមានកិច្ចប្រឹងប្រែងរួមគ្នា |
| ៣ | ត្រូវធ្វើឱ្យប្រាកដថារាល់កម្មវិធី និងការផ្តួចផ្តើមគំនិតទាំងអស់ ផ្អែកលើរបកគំហើញពីការស្រាវជ្រាវ និងបទពិសោធន៍ការងារជាក់ស្តែង |
| ៤ | ត្រូវធ្វើឱ្យប្រាកដថារាល់កម្មវិធីទាំងអស់មានជំនួយបច្ចេកទេសស្របនឹងបទដ្ឋានអន្តរជាតិ |
| ៥ | បំពាក់បំប៉នស្មារតីនៃភាពបន្ទាន់ ជំរុញគំនិតផ្តួចផ្តើមទាំងអស់ឱ្យមានដំណើរការទៅមុខដើម្បីទទួលបានលទ្ធផលជាក់ស្តែង |
| ៦ | រក្សាឱ្យបាននូវគុណភាព និងភាពជាក់លាក់ |
| ៧ | បង្ហាញនូវផលប៉ះពាល់ដែលអាចវាស់វែងបាន |
| ៨ | ជួយដល់អ្នកដែលត្រូវការឱ្យជួយ-អ្នកដែលងាយរងគ្រោះ និងអ្នកដែលត្រូវបានជួញដូរ |



# COMMIT SPA III, 2011-2013

# ផ្នែក 1. គោលនយោបាយនិងកិច្ចសហប្រតិបត្តិការ

# ផ្នែក 1. គោលនយោបាយនិងកិច្ចសហប្រតិបត្តិការ

### គោលបំណងនៅក្នុងអនុស្សរណៈនៃការយោគយល់ COMMIT

| | |
|---|---|
| មាត្រា 2 | កសាងផែនការសកម្មភាពរបស់ជាតិប្រឆាំងនឹងការជួញដូរមនុស្សគ្រប់ទម្រង់ទាំងអស់ |
| មាត្រា 3 | បង្កើត និងពង្រឹងគណៈកម្មាធិការជាតិពហុវិស័យ ស្តីពីការជួញដូរមនុស្សដែលមានអាណត្តិក្នុងការសម្របសម្រួល លើការអនុវត្តផែនការសកម្មភាពរបស់ជាតិ និងអន្តរាគមន៍ជួញដូរដទៃទៀត |
| មាត្រា 4 | បង្កើតយន្តការនានា ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ និងការផ្លាស់ប្តូរព័ត៌មាននៅថ្នាក់តំបន់ និងការកំណត់នូវស្ថាប័នបង្គោលរបស់ជាតិ ស្តីពីការប្រយុទ្ធប្រឆាំងការជួញដូរ |
| មាត្រា 5 | កែលម្អកិច្ចសហប្រតិបត្តិការប្រចាំតំបន់ ប្រឆាំងនឹងការជួញដូរ ជាពិសេសតាមរយៈកិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគី |
| មាត្រា 6 | ពង្រឹងកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាល អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស |
| មាត្រា 14 | លើកកម្ពស់កិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគី ក្នុងចំណោមប្រទេសនៅក្នុងមហាអនុតំបន់មេគង្គដើម្បីជួយគ្នាទៅវិញទៅមកនៅក្នុងដំណើរការតុលាការ |

# ផ្នែក 1: គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ

**ចំណុចដៅនានាសម្រាប់** COMMIT SPA III-2011-2013

| | |
|---|---|
| 1.1 | ផែនការសកម្មភាពជាតិ ត្រូវបានអនុម័តដើម្បីដោះស្រាយគ្រប់ទម្រង់នៃការជួញដូរ ដោយមានប្រព័ន្ធនានាដែលដំណើរការដើម្បីពិនិត្យតាមដាន និងរាយការណ៍អំពីការរីកចម្រើននិងលទ្ធផល ព្រមទាំងការបង្កើនថវិការបស់រដ្ឋាភិបាល ដែលបានផ្តល់ប្រចាំឆ្នាំសម្រាប់គាំទ្រដល់ជំហរ ពិធី យន្តការ ការប្រជុំ និងក្នុងការចំណាយដទៃទៀត ដើម្បីប្រឆាំងការជួញដូរ ។ប្រពន្ធ័ទាំងអស់នោះអាចរួមបញ្ចូលគណៈកម្មាធិការពហុវិស័យ ឬក្រុមការងារ នៅថ្នាក់ ជាតិនិងថ្នាក់ក្រោមជាតិ ។ |
| 1.2 | កម្មវិធីបណ្តុះបណ្តាលទូលំទូលាយនៅថ្នាក់ជាតិនិងថ្នាក់តំបន់ ត្រូវបានបង្កើតឡើង សម្រាប់អ្នកធ្វើការងារប្រឆាំង នឹងការការជួញដូរមនុស្ស មកពីរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល និងអ្នកកសាងគោលនយោបាយ (ការកសាងសមត្ថភាពជាទូទៅ និងឯកទេស) ដែលរៀបចំដោយក្រុមគ្រូបង្ហាត់ថ្នាក់ជាតិ |
| 1.3 | កិច្ចព្រមព្រៀងឆ្លងដែន ត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការ និងតាមដាន តាមទីកន្លែងដែលលំហូរការជួញដូរបង្ហាញអំពីតម្រូវការជាអាទិភាពឱ្យមានយន្តការនានា។ ផែនការសកម្មភាព និងនីតិវិធីប្រតិបត្តិការ ត្រូវបានដាក់ឱ្យអនុវត្ត ហើយផែនការអនុវត្តត្រូវបានពិនិត្យមើលរៀងរាល់ឆ្នាំ ។ |
| 1.4 | កិច្ចសហប្រតិបត្តិការប្រឆាំងនឹងការជួញដូរមនុស្សជាមួយរដ្ឋនានា និងស្ថាប័នពហុភាគី នៅខាងក្រៅតំបន់ COMMIT ត្រូវបានអនុវត្ត យ៉ាងមានប្រសិទ្ធភាព។ |
| 1.5 | កិច្ចសហប្រតិបត្តិការឆ្លងដែនប្រកបដោយប្រសិទ្ធភាព បានទទួលការគាំទ្រ និងគូសបញ្ជាក់ដោយយន្តការដែលមានដំណើរការ សម្រាប់ការប្រមូល វិភាគ និងផ្លាស់ប្តូរព័ត៌មានប្រកបដោយប្រសិទ្ធភាព រវាងក្រសួងនៃរដ្ឋាភិបាល និងសាធារណៈជន។ |
| 1.6 | បុគ្គលទាំងឡាយណាដែលរងគ្រោះដោយអំពើរជួញដូរមនុស្សដែលរួមមានជនរងគ្រោះនៃការជួញដូរត្រូវបានឱ្យចូលរួម និងផ្តល់អនុសាសន៍ នៅក្នុងការពិនិត្យតាមដាន និងការវាយតម្លៃនៃភាពលើប្រសិទ្ធភាពនៃកម្មវិធីប្រឆាំងការជួញដូរមនុស្ស។ |

## សាវតារ

ការកសាងគោលនយោបាយ បង្កើតជាមូលដ្ឋានសម្រាប់កិច្ចប្រឹងប្រែងរបស់រដ្ឋក្នុងការនាំខ្លួនជនល្មើសទៅកាត់ទោស និងកិច្ចការពារជនរងគ្រោះ ដែលជាការឆ្លើយតបទៅនឹងការជួញដូរមនុស្ស ក៏ដូចជា ក្នុងកិច្ចសហប្រតិបត្តិការឆ្លងដែន។ នៅក្រោម COMMIT SPA II, ទិដ្ឋភាពខាងគោលនយោបាយ ត្រូវបានដោះស្រាយ តាមរយៈផែនការសកម្មភាពជាតិ (PPC2) ភាពជាដៃគូទ្វេភាគី និងពហុភាគី (PPC3), ដោយប្រទេសនានានៅទូទាំងតំបន់នេះ កសាង និងអនុវត្តផែនការសកម្មភាពជាតិ និងកិច្ចព្រមព្រៀងឆ្លងដែន ដែលកាន់តែមានលក្ខណៈស្មុគស្មាញជាងមុន។

ការរីកចម្រើនយ៉ាងច្រើន បានធ្វើឡើង នៅក្នុងការឆ្លើយតបខាងគោលនយោបាយ នៅទូទាំងតំបន់ COMMIT ចាប់តាំងពីអនុស្សរណៈ COMMIT ចូលជាធរមាន និងតាមរយៈការអនុវត្ត COMMIT SPA I និង SPA II។ ការកំណត់អត្តសញ្ញាណ ឧក្រិដ្ឋកម្មនៃការជួញដូរមនុស្ស នៅក្នុងច្បាប់ជាតិ កាន់តែមានភាពទូលំទូលាយ និងស្របជាមួយស្តង់ដារអន្តរជាតិ ព្រមទាំងកំណត់វិធានការនានាដើម្បីឱ្យមាន ជំហាននៃការអនុវត្តកិច្ចព្រមព្រៀងរវាងប្រទេសនានា។ ផ្នែកនៃគោលនយោបាយ និងសកម្មភាព

នានានៅក្រោម COMMIT SPA III ព្យាយាមពង្រឹងសមិទ្ធិផលទាំងនេះ និងធានាថា ផ្នែកនៃគោលនយោបាយ ត្រូវបានអនុវត្តពេញលេញ ដូចដែលគ្រោងទុក ដើម្បីពង្រឹងកិច្ចប្រឹងប្រែងប្រឆាំងការជួញដូរមនុស្ស។ ការសម្របសម្រួលជាមួយផែនការ ផ្សេងទៀតដែល ទាក់ទងនៅថ្នាក់ជាតិ ដូចជា ផែនការនានាដែលចែងអំពីការប្តេជ្ញានៅក្នុងក្របខ័ណ្ឌនៃអនុសញ្ញាសហប្រជាជាតិស្តីពី សិទ្ធិកុមារ (CRC) ឬ អនុញ្ញាសហប្រជាជាតិដើម្បីលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី (CEDAW), ក៏ជួយផងដែរក្នុងការបញ្ជៀសការត្រួតគ្នានៃដំណើរការនានារបស់រដ្ឋាភិបាល។

សមត្ថភាពរបស់មន្ត្រីរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការប្រឆាំងការជួញដូរមនុស្ស ក្នុងការធ្វើសេចក្តីសម្រេចខាងគោលនយោបាយ ប្រកបដោយការយល់ដឹងជាមុន មានភាពប្រសើរច្រើន នៅក្នុងអំឡុងពេល SPA I និង SPA II ជាមួយការដាក់ឱ្យអនុវត្ត និងការកែលម្អកម្មវិធីបណ្តុះបណ្តាលនៅថ្នាក់តំបន់។ COMMIT SPA III នឹងត្រូវកែលម្អជាបន្ថែម រួមបញ្ចូលគ្នា និង ធ្វើឱ្យមានលក្ខណៈជាស្តង់ដារ នូវការបណ្តុះបណ្តាលនេះ និងការបណ្តុះបណ្តាលឯកទេសដទៃទៀត នៅថ្នាក់ជាតិនិងថ្នាក់តំបន់ ដែលរៀបចំដោយគ្រូបង្គាត់មកពីរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ដែលជាគ្រូបង្គាត់មានការបញ្ជាក់ពីកម្រិតសមត្ថភាព។

## សកម្មភាពរបស់ផែនការសកម្មភាពអនុតំបន់ទី៣ (COMMIT SPA III -2011-2013)

| សកម្មភាព | | សេចក្តីអធិប្បាយ |
|---|---|---|
| ★P&C 1<br>ចំណុចដៅ ១.១ | ការគាំទ្រដល់ផែនការសកម្មភាពជាតិ | គាំទ្រដល់ការបង្កើតផែនការសកម្មភាពជាតិ រួមទាំងការបង្កើតប្រព័ន្ធពិនិត្យតាមដាន វាយតំលៃ និងរាយការណ៏សម្រាប់ផែនការជាតិប្រឆាំងការជួញដូរមនុស្សដើម្បីធានាឱ្យមានការអនុវត្តសកម្មភាពរបស់ផែនការជាតិ និងសម្រួលដល់ការធ្វើសុខុដុម្មនីយកម្មនូវសកម្មភាពជាតិប្រឆាំងការជួញដូរមនុស្ស ឆ្ពោះទៅសម្រេចគោលបំណង និងគោលដៅរបស់ផែនការសកម្មភាពជាតិ ។ |
| ★P&C 2<br>ចំណុចដៅ ១.២ | ការបណ្តុះបណ្តាល និងកសាងសមត្ថ ភាពសម្រាប់អ្នកឆ្លើយតប និងអ្នកកសាងគោលនយោបាយនៅថ្នាក់ជាតិ | ផ្តល់ការបណ្តុះបណ្តាលទូទៅ និងឯកទេសនៅថ្នាក់ តំបន់ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់អ្នកឆ្លើយតបនឹងការជួញដូរមនុស្ស និងអ្នកកសាង គោលនយោបាយ ដោយប្រើប្រាស់សម្ភារថ្មីៗបំផុតនិងគ្រូបង្ហាត់ដែលមានវិញ្ញាប័ណ្ណប័ត្របញ្ជាក់ ។ |
| P&C 3<br>ចំណុចដៅ ១.៣ | អនុវត្តកិច្ចព្រមព្រៀងឆ្លងដែន | គាំទ្រដល់ការអនុវត្តកិច្ចព្រមព្រៀងសម្រាប់សហប្រតិបត្តិការឆ្លងដែន/ទ្វេភាគី ស្តីពីការជួញដូរមនុស្ស ដែលគាំទ្រដោយថវិកាជាតិ និងមន្ត្រីរដ្ឋាភិបាលពីក្រសួង និងនាយកដ្ឋានសមស្របបំផុត ។ ប្រការ នេះរួម មានការគាំទ្រដើម្បីឱ្យមានការកែលម្អលើការសម្របសម្រួលការ អនុវត្ត ច្បាប់ និងបណ្តាញការពារជនរងគ្រោះនៅលំដាប់ប្រតិបត្តិការ ដែលរួម ទាំង ការធ្វើមាតុភូមិនិវត្តន៏ជនរងគ្រោះ និងការផ្តោះប្តូរព័តិមាន និងភស្តុតាង សម្រាប់ការនាំយកជនល្មើសមកកាត់ទោសផងដែរ ។ |
| P&C 4<br>ចំណុចដៅ ១.៤ | គាំទ្រដល់កិច្ចសហប្រតិបត្តិការជាមួយនឹងប្រទេសក្រៅពីតំបន់ COMMIT | គាំទ្រឱ្យមានការដាក់ឱ្យអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគី ជាមួយប្រទេសនានា និងស្ថាប័នពហុភាគី ផ្សេងៗទៀតមិនត្រឹមតែក្នុង តំបន់មេគង្គឡើយ ដែលពួកគេអាចបង្ហាញពីការគាំទ្រដល់កិច្ច ប្រឹងប្រែងប្រឆាំងការជួញដូរមនុស្ស ។ |
| P&C 5<br>ចំណុចដៅ ១.៥ | ការផ្លាស់ប្តូរព័តិមានឆ្លងដែន | ការផ្តោះប្តូរព័តិមាន ដែលធ្វើឡើងប្រកបដោយប្រសិទ្ធភាព និងផ្តល់ផលក្នុងការប្រយុទ្ធប្រឆាំងបណ្តាញជួញដូរមនុស្សឆ្លងដែន ត្រូវបានវាយតម្លៃនៅមូលដ្ឋាន តាមព្រំប្រទល់ដើម្បីឱ្យមានចំណាត់ការឆ្លើយតប ក៏ដូចជានៅថ្នាក់កណ្តាលឱ្យបានញឹកញាប់ផងដែរ ។ |

| | | |
|---|---|---|
| P&C 6<br>ចំណុចដៅ ១.៦ | ការចូលរួម និងការពិគ្រោះយោបល់ជាមួយបុគ្គលនានាដែលរងគ្រោះដោយសារការជួញដូរមនុស្ស | ការពិគ្រោះយោបល់ជាមួយបុគ្គលនានាដែលរងគ្រោះពីការជួញដូរមនុស្ស ដែលរួមទាំង ជនរងគ្រោះពីការជួញដូរ និងក្រុមជនងាយរងគ្រោះ កុមារ និងយុវជន ដើម្បី ទទួលបានយោបល់ពីពួកគេ សម្រាប់សកម្មភាពនៅថ្នាក់ជាតិ ក្នុងការប្រឆាំង នឹងការជួញដូរមនុស្ស។ |

# COMMIT SPA III, 2011-2013

# ផ្នែក 2. ក្របខ័ណ្ឌច្បាប់ ការអនុវត្តច្បាប់ និងយុត្តិធម៌

# ផ្នែក 2. ក្របខ័ណ្ឌច្បាប់ ការអនុវត្តច្បាប់ និងយុត្តិធម៌

## គោលបំណងនៅក្នុងអនុស្សរណៈនៃការយោគយល់របស់ COMMIT

| | |
|---|---|
| មាត្រា 1 | លើកទឹកចិត្តឱ្យមានការប្រើប្រាស់និយមន័យអំពីការជួញដូរ ដូចមានចែងនៅក្នុងពិធីសារដើម្បីទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្មដល់ការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ ដែលជាការបំពេញបន្ថែមលើអនុសញ្ញាសហប្រជាជាតិស្តីពីឧក្រិដកម្មឆ្លងប្រទេសដែលមានអង្គការចាត់តាំង ។ |
| មាត្រា 7 | ការអនុម័តនិងពង្រឹងការអនុវត្តច្បាប់សមស្របប្រឆាំងការជួញដូរមនុស្សឱ្យបានឆាប់តាមតែអាចធ្វើបាន ។ |
| មាត្រា 9 | ស៊ើបអង្កេត ឃាត់ខ្លួន យកមកកាត់ទោស និងដាក់ទណ្ឌកម្មជនល្មើសក្នុងការជួញដូរមនុស្ស ស្របតាមច្បាប់ជាតិ ។ |
| មាត្រា 11 | បង្កើតកិច្ចសហប្រតិបត្តិការជាក់ស្តែង និងមានប្រសិទ្ធភាព លើប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ដើម្បីលុបបំបាត់និទណ្ឌភាពសម្រាប់អ្នកជួញដូរមនុស្ស និងផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ ។ |
| មាត្រា 12 | ពង្រឹងកិច្ចសហប្រតិបត្តិការឆ្លងដែនលើការពង្រឹងការអនុវត្តច្បាប់ ក្នុងចំណោមប្រទេសទាំងប្រាំមួយ នៅក្នុងមហាអនុតំបន់មេគង្គ ដើម្បីប្រយុទ្ធប្រឆាំងការជួញដូរ តាមរយៈដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ ។ |
| មាត្រា 13 | ផ្តល់ការគាំទ្រចាំបាច់ ជាបុគ្គលិក និងថវិកា សម្រាប់សមត្ថភាពឆ្លើយតបនឹងការជួញដូរ នៅក្នុងការកសាងសមត្ថភាពនៅក្នុងចំណោមមន្ត្រីអនុវត្តច្បាប់ នៅក្នុងប្រទេស ។ |

## ចំណុចដៅនានាសម្រាប់ COMMIT SPA III-2011-2013

| | |
|---|---|
| 2.1 | ច្បាប់ទូលំទូលាយស្តីពីការជួញដូរមនុស្ស ស្របជាមួយនិយមន័យអន្តរជាតិ ត្រូវបានចូលជាធរមាន និងដាក់ ឱ្យអនុវត្តពេញលេញនៅក្នុងប្រទេស COMMIT ទាំងអស់ ។ ច្បាប់ព្រហ្មទណ្ឌផ្សេងទៀតទាំងអស់ ក៏អាចអនុវត្តបានផងដែរ នៅក្នុងករណីព្រហ្មទណ្ឌនៃការជួញដូរមនុស្ស និងអ្នកស៊ើបអង្កេត ពិចារណាផ្តន្ទាទោស លើគ្រប់ រូបភាពនៃបទល្មើសដែលបានប្រព្រឹត្ត ។ |
| 2.2 | មន្ត្រីអនុវត្តច្បាប់ បានទទួលការបណ្តុះបណ្តាលសមស្រប និងប្រតិបត្តិការ ទៅតាមមុខនាទីរបស់ខ្លួន ដែលរួម ទាំងអង្គភាពឯកទេសប្រឆាំងការជួញដូរមនុស្ស និងនគរបាល ដែលអនុវត្តមុខនាទីទូទៅ និងមន្ត្រីអន្តោប្រវេសន៍នៅក្នុងតំបន់ដែលមានការជួញដូរច្រើន ។ នេះរួមបញ្ចូលការកំណត់អត្តសញ្ញាណជនរងគ្រោះប្រកបដោយប្រសិទ្ធភាព និងបច្ចេកទេសស៊ើបអង្កេតករណីជួញដូរមនុស្ស និងមានការស៊ើបអង្កេត និងការដាក់ទណ្ឌកម្ម លើការឃុបឃិត និងអំពើពុករលួយនៅក្នុងចំណោមមន្ត្រីអនុវត្តច្បាប់ ។ |
| 2.3 | អ្នកស៊ើបអង្កេត និងព្រះរាជអាជ្ញា ដែលបានពាក់ព័ន្ធនៅក្នុងការឆ្លើយតបខាងយុត្តិធម៌ព្រហ្មទណ្ឌតបទៅនឹង ការជួញដូរមនុស្ស ទទួលបានការបណ្តុះបណ្តាលអំពីទិដ្ឋភាពបច្ចេកទេសដែលពាក់ព័ន្ធជាមួយឧក្រិដ្ឋកម្មដោយ មានការគាំទ្រដល់កិច្ចសហប្រតិបត្តិការពហុវិស័យ យន្តការកសាងសមត្ថភាពរួមគ្នា និងបណ្តាញមន្ត្រីអនុវត្តច្បាប់ ព្រះរាជអាជ្ញា និងចៅក្រម ។ |
| 2.4 | គាំទ្រដល់ការបង្កើនគុណភាពដែលអាចវាស់បាន ខាងការឆ្លើយតបនៃយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរមនុស្សដែលរួមទាំង(ក)ការធ្វើសមាហរណកម្មបានប្រសើរជាងមុនជាមួយការឆ្លើយតបខាងផ្នែកសេវាកម្ម ជនរងគ្រោះ (ខ) ស្តង់ដារអន្តរជាតិ នៃដំណើរការចាំបាច់ និងភាពត្រឹមត្រូវដែលអនុវត្តនៅក្នុងការស៊ើបអង្កេត និងផ្តន្ទាទោសករណីជួញដូរមនុស្ស (គ)ការទូទាត់សំណងដែលប្រើប្រាស់ ជាការបំពេញបន្ថែម ពីលើកិច្ចប្រឹងប្រែងខាងយុត្តិធម៌ព្រហ្មទណ្ឌ ដែលផ្តល់ជម្រើសបន្ថែមសម្រាប់ជនរងគ្រោះ ដែលស្វែងរកការគាំទ្រខាងផ្លូវច្បាប់ (ឃ) ចៅក្រមយល់ដឹងអំពីតួនាទីរបស់ពួកគេ ក្នុងនាមជាអាជ្ញាកណ្តាលឯករាជ្យនិងគ្មានការលំអៀងនៅក្នុងករណីជួញដូរមនុស្ស ដោយសង្កត់ធ្ងន់លើការបង្ហាញអំពីភស្តុតាងដែលគួរជឿបាន នៅក្នុងករណីនានា និងការដាក់ទម្ងន់ទោស ដោយគ្មានការសង្ស័យសមហេតុផល ។ |

## សាវតារ

ការឆ្លើយតបខាងយុត្តិធម៌ព្រហ្មទណ្ឌចំពោះការជួញដូរមនុស្ស ត្រូវបានបង្កើតឡើងនៅក្នុងអំឡុង COMMIT SPA II នៅក្រោម PPC4 "ក្របខ័ណ្ឌច្បាប់ ការអនុវត្តច្បាប់ និងយុត្តិធម៌"។ សកម្មភាពនានា ដែលអនុវត្តនៅអំឡុងពេលនេះ មានការរីកចម្រើនយ៉ាងច្រើននៅក្នុងការអនុវត្តកិច្ចប្រឹងប្រែងលើវិស័យជាច្រើននៃការប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេស ដោយមានការគាំទ្រពីគម្រោងការជួញដូរមនុស្សនៅតំបន់អាស៊ី (ARTIP) ក្រោមការគាំទ្រមូលនិធិពីទីភ្នាក់ងារអូស្ត្រាលីសម្រាប់កិច្ចអភិវឌ្ឍន៍អន្តរជាតិ (AusAID)។ កិច្ចប្រឹងប្រែងទាំងនេះ រួមមាន សកម្មភាពនានា ដូចជា ការគាំទ្រដល់ការបង្កើតអង្គភាពជំនាញឯកទេសនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិប្រឆាំងនឹងការ ជួញដូរមនុស្ស និងការបណ្តុះបណ្តាលអំពីការប្រឆាំងនឹងការជួញដូរមនុស្សសម្រាប់អ្នកដែលនៅក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ។

ការពិនិត្យឡើងវិញនូវករណីជួញដូរមនុស្ស ដែលត្រូវបានធ្វើឡើង តាមរយៈប្រព័ន្ធយុត្តិធម៌ នៅក្នុងប្រទេសមួយចំនួនក្នុងក្របខ័ណ្ឌ COMMIT ត្រូវបានអនុវត្ត ដោយការវិភាគនេះផ្តល់ព័ត៌មានអំពីការឆ្លើយតបខាងយុត្តិធម៌ព្រហ្មទណ្ឌជាទូទៅ និងក្នុងបំណងកែលម្អគុណភាពនៃការផ្តន្ទាទោសនៅក្នុងវិស័យនេះ។

នៅក្រោម COMMIT SPA III, ផ្នែកនៃយុត្តិធម៌ព្រហ្មទណ្ឌ មានបំណងពង្រឹងជាបន្ថែមដោយផ្អែកលើមូលដ្ឋានគ្រឹះដែលបានបង្កើតឡើងនៅក្នុងពេល COMMIT SPA I និង SPA II។ សកម្មភាពនានា បានធ្វើឡើង ដោយផ្អែកលើការវិភាគអំពីការអភិវឌ្ឍនានានៅក្នុងវិស័យនេះនៅក្នុងអំឡុងពេល COMMIT SPA II និងស្តង់ដារគុណភាពជាអន្តរជាតិ ដែលបានលើកស្នើជាមូលដ្ឋានសម្រាប់ការឆ្លើយតបឱ្យបានខ្លាំងក្លាខាងយុត្តិធម៌ព្រហ្មទណ្ឌ ទៅនឹងការជួញដូរមនុស្សនៅក្នុងកម្មវិធីបណ្តុះបណ្តាលប្រឆាំងនឹងការជួញដូរមនុស្សនៅក្រោម COMMIT :

1. ក្របខ័ណ្ឌច្បាប់ដែលមានប្រសិទ្ធភាព
2. ការឆ្លើយតបរបស់នគរបាលឯកទេស
3. ការឆ្លើយតបខាងការអនុវត្តច្បាប់នៅជួរមុខ
4. ការឆ្លើយតបផ្នែកផ្តន្ទាទោសនិងតុលាការ
5. ការកំណត់អត្តសញ្ញាណជនរងគ្រោះត្រឹមត្រូវ និងការផ្តល់នូវកិច្ចការពារ និងការគាំទ្រ នៅពេលដែលជនរងគ្រោះត្រូវបានកំណត់អត្តសញ្ញាណ
6. គាំទ្រដល់ជនរងគ្រោះសម្រាប់ឱ្យធ្វើជាសាក្សី
7. កិច្ចសហប្រតិបត្តិការអន្តរជាតិ និង
8. សម្របសម្រួលការគាំទ្រដល់ការឆ្លើយតបខាងព្រហ្មទណ្ឌយុត្តិធម៌ចំពោះការជួញដូរមនុស្ស។

សមត្ថភាពពង្រឹងការនុវត្តច្បាប់ និងមន្ត្រីខាងផ្នែកច្បាប់ ក្នុងការអនុវត្តមុខការរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព បានកែលម្អយ៉ាងច្រើននៅក្នុងអំឡុងពេល COMMIT SPA I និង SPA II ដោយការផ្តល់នូវការបណ្តុះបណ្តាលឯកទេសជាច្រើនពីដៃគូខុសៗគ្នាជាច្រើន។ SPA III នឹងត្រូវកែលម្អបន្ថែមទៀត និងបង្កើតឱ្យទៅជាស្តង់ដារ នូវការបណ្តុះបណ្តាលឯកទេសនៅថ្នាក់ជាតិ ដោយប្រើប្រាស់គ្រូបង្គោលពីរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលដែលជាអ្នកមានវិញ្ញាបនប័ត្របញ្ជាក់ និងមានគោលដៅពង្រឹងបណ្តាញប្រតិបត្តិករផ្នែកស៊ើបអង្កេត ផ្តន្ទាទោស និងតុលាការ នៅថ្នាក់ជាតិ និងថ្នាក់តំបន់។

**សកម្មភាពភាពសម្រាប់ COMMIT SPA III-2011-2013**

| សកម្មភាព | | សេចក្ដីអធិប្បាយ |
|---|---|---|
| ★CJ 1 ចំណុចដៅ ២.១ | ច្បាប់ស្ដីពីការជួញដូរមនុស្ស ដោយប្រើ ប្រាស់និយមន័យអន្តរជាតិ អំពីការជួញដូរមនុស្ស និងការអនុវត្តច្បាប់ ដទៃទៀតប្រឆាំងអ្នកជួញដូរមនុស្ស | គាំទ្រដល់ការវិភាគ ការរៀបរៀងសេចក្ដីព្រាង ការតាក់តែង និងការអនុវត្តច្បាប់ស្ដីពីការជួញដូរមនុស្ស ដែលឱ្យនិយមន័យបទឧក្រិដ្ឋនេះ ស្របជាមួយនិយមន័យអន្តរជាតិ ត្រូវបានកំណត់ដាច់ដោយឡែក ពីឧក្រិដ្ឋកម្ម ដទៃទៀត និងចែងអំពីការគាំទ្រដល់ជនរងគ្រោះ។ បទ ល្មើសព្រហ្មទណ្ឌ ដែលពាក់ព័ន្ធ រួមមានច្បាប់ប្រឆាំងអំពើទាសភាព ដើម្បីដោះបំណុល និងការរំលោភច្បាប់ការងារ អន្តោប្រវេសន៍ ឬ លាង លុយកខ្វក់ក៏ត្រូវ បានពិនិត្យឡើងវិញតាមការចាំបាច់/សមស្រប សម្រាប់ ភាពអនុវត្តបាន និងត្រូវបានពិចារណានៅក្រោមអភិក្រមរួមដើម្បីតាមរកជនល្មើស។ |
| CJ 2 ចំណុចដៅ ២.២ | ពង្រឹងអង្គភាពឯកទេសផ្នែកអនុវត្តច្បាប់ ប្រឆាំងការជួញដូរមនុស្ស | គាំទ្រដល់ការបង្កើត និងពង្រឹងអង្គភាពឯកទេសអនុវត្តច្បាប់ប្រឆាំងការជួញដូរមនុស្ស ដែលមានដំណើរការ ដោយមានធនធាន និង ជំនាញគ្រប់គ្រាន់ ដើម្បីឆ្លើយតបនឹងការជួញដូរមនុស្សដោយប្រសិទ្ធភាព និងដោយគិតទុកជាមុន នៅក្នុងបរិបទជាតិ។ |
| CJ 3 ចំណុចដៅ ២.២ | ការគាំទ្រការស៊ើបអង្កេតបុរេសកម្ម | គាំទ្រដល់ការស៊ើបអង្កេតករណីជួញដូរមនុស្សត្រូវបានអនុវត្ត និងចងក្រង ជាឯកសារ ដោយមានករណីខ្លះបានឈានទៅនាំយកអ្នកទទួលផលចម្បងៗ ពីបណ្ដាញព្រហ្មទណ្ឌមកកាត់ទោស ការស៊ើបអង្កេតនានាដែលបានធ្វើ ឡើងដោយគ្មាន ការពឹងផ្អែកហួសហេតុ តែលើជនរងគ្រោះជាសាក្សី។ |
| ★CJ 4 ចំណុចដៅ ២.៣ | ពង្រឹងការសម្របសម្រួលការឆ្លើយតបខាង ព្រហ្មទណ្ឌយុត្តិធម៌ជាមួយកិច្ចការពារជនរងគ្រោះ | ឧបត្ថម្ភគាំទ្រដល់អ្នកឆ្លើយតបនឹងយុត្តិធមិព្រហ្មទណ្ឌ និង អ្នកផ្ដល់សេវាកម្មជួយជនរងគ្រោះ ដើម្បី កែលម្អបទពិសោធន៍ របស់ជនរងគ្រោះក្នុងការចូលរួមដោយយល់ដឹងជាមុននិងតាមឆន្ទៈ នៅក្នុងដំណើរការយុត្តិធមិព្រហ្មទណ្ឌ តាមបរិបទរបស់ប្រទេសនីមួយៗ ដោយពិចារណាផងដែរតម្រូវការ របស់ជនរងគ្រោះ និងការផ្ដល់កិច្ចការពារដល់ជនរងគ្រោះ និង សាក្សី នៅក្នុងគ្រប់ដំណាក់កាលនៃករណីព្រហ្មទណ្ឌ។ ជារួម ការបង្កើត និងពង្រឹងកិច្ចការពារតាមផ្លូវច្បាប់ដល់ជនរងគ្រោះ គ្រួសារ សាក្សី និងអ្នកផ្ដល់ព័ត៌មាន ដែលរួមទាំង ការទូទាត់សំណង និង |

| | | |
|---|---|---|
| | | វិធានការស្តារនីតិសម្បទាសម្រាប់ជនរងគ្រោះពីការជួញដូរ ការផ្តល់ឱកាសសម្រាប់ការទាមទាររបស់ជនរងគ្រោះនៅក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ករណីរដ្ឋប្បវេណី និងក្រមច្បាប់ការងារ វិធានការការពារជនរងគ្រោះ និងសាក្សី ដែលរួមទាំង កិច្ចការពារកុមារមេត្រីតាមការចាំបាច់ ហើយវិធានការការពារត្រូវអនុវត្តតែនៅក្រោយមានការពិគ្រោះយោបល់ជាមួយនិង ការឯកភាពពីជនរងគ្រោះជាមនុស្សពេញវ័យ និងកិច្ចការពារបន្ថែមនិង យុទ្ធសាស្រ្តផ្តន្ទាទោសត្រូវបានផ្តល់ដើម្បីធានាសុវត្ថិភាពជនរងគ្រោះ ។ |
| CJ 5<br>ចំណុចដៅ ២.៣ | ការបណ្តុះបណ្តាលឯកទេស និង បណ្តាញសម្រាប់អ្នកឆ្លើយតបក្នុងទីភ្នាក់ងារព្រហ្មទណ្ឌយុត្តិធម៌ | ការបណ្តុះបណ្តាល និងការបង្កើតឱ្យមានបណ្តាញគាំទ្រដល់អ្នកទាំងអស់ដែលពាក់ព័ន្ធនៅក្នុងការឆ្លើយតបនៃយុត្តិធម៌ព្រហ្មទណ្ឌ ដែលទាក់ទងនឹងទិដ្ឋភាព បច្ចេកទេសមស្របអំពីតួនាទីរបស់ពួកគេដែលទាក់ទងនឹងច្បាប់ និងការពារជនរងគ្រោះផងដែរ ។ ការគាំទ្រដល់បណ្តាញនានានៃមន្រ្តីពង្រឹងការអនុវត្តច្បាប់សំខាន់ៗ និងព្រះរាជអាជ្ញា ដោយផ្តោតលើករណីជួញដូរឆ្លងដែន រួមជាមួយការពិគ្រោះយោបល់ថ្នាក់តំបន់ និងទ្វេភាគី លើការសម្របសម្រួលករណី និងយុទ្ធសាស្រ្តនានាដែលចាំបាច់ ។ |
| CJ 6<br>ចំណុចដៅ ២.៤ | ពិនិត្យតាមដានករណីជួញដូរមនុស្ស ដើម្បីធ្វើឱ្យប្រាកដថា មានការប្រុងប្រយ័ត្ន និងដំណើរការត្រឹមត្រូវក្នុងការផ្តន្ទាទោស | មានវិធានការសមស្រប សម្រាប់តាមដាន ដើម្បីតាមដានការនាំខ្លួនទៅ កាត់ទោសនូវករណីជួញដូរមនុស្ស ដើម្បីធានាថា ការវិនិច្ឆ័យក្តីបានធ្វើឡើងស្របតាមកម្រិតនៃបទព្រហ្មទណ្ឌ និងមានភស្តុតាងគ្រប់គ្រាន់ សម្រាប់គាំទ្រដល់ការចេញសាលក្រម ដែលរួមទាំងតាមរយៈកម្មវិធីឃ្លាំមើលតុលាការ ការវិភាគករណី និងការពិគ្រោះយោបល់បច្ចេកទេស ។ |
| CJ 7<br>ចំណុចដៅ ២.៤ | ពង្រឹងលទ្ធភាពរបស់ជនរងគ្រោះក្នុងការ ទទួលបានសេវាកម្មយុត្តិធម៌ និងការទូទាត់ សំណងតាមរយៈការជួសជុល សំណងរដ្ឋប្បវេណី | យន្តការច្បាប់រដ្ឋប្បវេណី ជាពិសេស ការទូទាត់សំណង និងសិទ្ធិភាពការងាររបស់ជនរងគ្រោះ ការពិនិត្យឡើងវិញ នៅក្នុង ប្រទេស COMMIT នីមួយៗ ដែលនាំឱ្យមានការរៀបចំឯកសារណែនាំសម្រាប់ ប្រតិបត្តិករនៅក្នុងប្រទេសនីមួយៗ របាយការណ៍សម្រាប់ក្រុមការងារ COMMIT និងការបណ្តុះបណ្តាលដែលពាក់ព័ន្ធ ព្រមទាំងការផ្សព្វផ្សាយ ព័ត៌មានអំពីច្បាប់រដ្ឋប្បវេណីនៅក្នុងបរិបទឯកជន រដ្ឋាភិបាលនិងស្ថាប័នអប់រំ ។ |

# COMMIT SPA III, 2011-2013

# ផ្នែក 3. កិច្ចការពារ ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្ម

# ផ្នែក 3. កិច្ចការពារ ការស្តារនីតិសម្បទា និងការធ្វើសមាហ រណកម្ម

## គោលបំណងនៅក្នុងអនុស្សរណៈនៃការយោគយល់របស់ COMMIT

| | |
|---|---|
| មាត្រា 8 | អនុម័តគោលការណ៍ណែនាំសមស្រប និងផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីពាក់ព័ន្ធដើម្បីឱ្យ ពួកគេអាចកំណត់អត្តសញ្ញាណជនរងការជួញដូរបានឆាប់រហ័ស និងសុក្រឹត្យនិងកែលម្អការស៊ើបអង្កេត ការនាំខ្លួនមកកាត់ទោស និងដំណើរការក្នុងតុលាការ ។ |
| មាត្រា 10 | ផ្តល់ឱ្យជនរងគ្រោះនៃការជួញដូរ នូវជំនួយខាងផ្នែកច្បាប់និងព័ត៌មានជាភាសាដែលពួកគេយល់ ។ |
| មាត្រា 15 | លើកកម្ពស់ការយកចិត្តទុកដាក់បានច្រើនថែមទៀតអំពីយេនឌ័រ និងកុមារ នៅក្នុងគ្រប់វិស័យ ដែលធ្វើការជាមួយជនរងគ្រោះនៃការជួញដូរ ។ |
| មាត្រា 16 | ធានាថា ជននានាដែលបានកំណត់អត្តសញ្ញាណថាជាជនរងគ្រោះនៃការជួញដូរ មិនត្រូវរក្សាទុកក្នុងទីឃុំឃាំង ដោយអាជ្ញាធរអនុវត្តច្បាប់ឡើយ ។ |
| មាត្រា 17 | ផ្តល់ឱ្យជនរងគ្រោះនៃការជួញដូរទាំងអស់នូវជម្រក និងជំនួយរូបវន្ត ចិត្ត-សង្គម ច្បាប់ ការអប់រំ និងការថែទាំសុខភាព ។ |
| មាត្រា 18 | អនុម័តគោលនយោបាយ និងយន្តការនានា ដែលការពារ និងគាំទ្រដល់អ្នកដែលបានក្លាយជនរងគ្រោះនៃការជួញដូរមនុស្ស ។ |
| មាត្រា 19 | ពង្រឹងសមត្ថភាពរបស់ស្ថានទូត និងស្ថានកុងស៊ុល ដើម្បីធានាថា ពួកគេអាចជួយជនរងគ្រោះ ពីការជួញដូរមនុស្សប្រកបដោយប្រសិទ្ធភាពជាងមុន ។ |
| មាត្រា 20 | ធានាឱ្យមានកិច្ចសហប្រតិបត្តិការឆ្លងដែនលើការធ្វើមាតុភូមិនិវត្តជនរងគ្រោះពីការជួញដូរដោយសុវត្ថិភាព ដែលរួមទាំង ការគាំទ្រដើម្បីធានាសុខុមាលភាពរបស់អ្នកទាំងនោះ ។ |
| មាត្រា 21 | ធ្វើការជាមួយគ្នា ដើម្បីសម្រួលឱ្យមានការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មឡើងវិញសម្រាប់ជនរងការជួញដូរ និងទប់ស្កាត់កុំឱ្យពួកគាត់ត្រូវបានគេជួញដូរទៀត នៅពេលអនាគត ។ |

## ចំណុចដៅសម្រាប់ COMMIT SPA III-2011-2013

| | |
|---|---|
| 3.1 | ប្រព័ន្ធ និងគោលការណ៍ណែនាំ ត្រូវដាក់ឱ្យអនុវត្ត និងដំណើរការ ដើម្បីធានាថា ជនរងគ្រោះនៃការជួញដូរ ត្រូវបានកំណត់អត្តសញ្ញាណ និងទទួលជំនួយជាលក្ខណៈបុគ្គល សមស្របទៅតាមភេទ និងអាយុ បន្ទាប់ពី ការកំណត់អំពីឧត្តមប្រយោជន៍ខ្ពស់បំផុតរបស់ជនរងគ្រោះ ។ ផ្តល់ព័ត៌មានតាមភាសាដែលពួកគេអាចយល់បាន ការកែលម្អការកំណត់អត្តសញ្ញាណជនរងគ្រោះ ជាបន្តបន្ទាប់ ដែលអាចវាស់បាន តាមរយៈការវាយ តម្លៃ និងទទួលបានចម្លើយតបពីជនរងគ្រោះ ។ |
| 3.2 | ប្រព័ន្ធ និងគោលការណ៍ណែនាំ ត្រូវបានដាក់ឱ្យអនុវត្ត និងមានដំណើរការ ដើម្បីធានាថាជនរងគ្រោះនៃការជួញដូរមិនស្ថិតក្រោមការឃុំឃាំង ពីសំណាក់អាជ្ញាធរអនុវត្តច្បាប់ ឬនៅតាមជម្រំ ឬកន្លែងឃុំគ្រងដទៃទៀត មិនស្របតាមឆន្ទៈរបស់ជនរងគ្រោះ ។ |
| 3.3 | ប្រព័ន្ធ និងគោលការណ៍ណែនាំ ត្រូវបានដាក់ឱ្យអនុវត្តនិងដំណើរការ ដើម្បីធានាថា ជនរងគ្រោះនៃការជួញដូរ បានទទួលជម្រើសដែលមានសុវត្ថិភាព និងទាន់ពេលវេលា សម្រាប់ការវិលត្រឡប់ និងមាតុភូមិនិវត្តន៍ ជាមួយការកែលម្អកិច្ចសហប្រតិបត្តិការឆ្លងដែនជាបន្តបន្ទាប់ ដែលវាស់តាមរយៈការវាយតម្លៃ និងការឆ្លើយតបពីជនរងការជួញដូរ ។ |
| 3.4 | ប្រព័ន្ធ និងគោលការណ៍ណែនាំ ត្រូវបានដាក់ឱ្យអនុវត្ត និងមានដំណើរការ ដើម្បីធានាថា ជនរងគ្រោះនៃការជួញដូរ បានទទួលជម្រើសសមាហរណកម្មសមស្រប ជាលក្ខណៈបុគ្គល ដែលរួមទាំងជម្រើសសមស្រប និងមាននិរន្តរភាពនៃរបរចិញ្ចឹមជីវិត ជាមួយការកែលម្អសេវាកម្មជាបន្តបន្ទាប់ ដែលអាចវាស់បានតាមរយៈការវាយតម្លៃ និងចម្លើយតបពីជនរងការជួញដូរ ដែលជាអតិថិជន ។ |
| 3.5 | ក្រុមអ្នកផ្តល់សេវាកម្មជួយជនរងគ្រោះដែលជាក្រុមមន្ត្រីបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ មានបណ្តាញ និងដំណើរការនៅក្នុងតួនាទីរៀងៗខ្លួន តាមស្តង់ដារអន្តរជាតិ ដែលទាក់ទងនឹង ទាំងគុណភាពនៃការថែទាំ និងក្រមសីលធម៌នៃការយកចិត្តទុកដាក់ ចំពោះក្រុមមនុស្សដែលរងគ្រោះនៃការជួញដូរ ។ |

### សាវតារ

ការយកចិត្តទុកដាក់នៃសកម្មភាពការពារជនរងគ្រោះនៅក្រោម COMMIT SPA II (2008-2010) គឺការគាំទ្រដល់ការបង្កើតគោលការណ៍ណែនាំថ្នាក់តំបន់ និងជាតិ សម្រាប់ការធ្វើអត្តសញ្ញាណ មាតុភូមិនិវត្តន៍ និងគុណភាពនៃការថែទាំនៅក្នុងសេវាការពារជនរងគ្រោះ ។ រដ្ឋាភិបាលនៅក្នុង COMMIT បង្កើតគោលការណ៍ណែនាំនៅថ្នាក់តំបន់សម្រាប់ការពារជនរងគ្រោះពីការជួញដូរនៅក្នុងឆ្នាំ 2007, មុននឹងការអនុម័តលើ COMMIT SPA II, បន្ទាប់មកផ្តោតលើការបង្កើតគោលការណ៍ណែនាំ និងនីតិវិធីជាតិ ដើម្បីដាក់ឱ្យអនុវត្តដំណើរការកំណត់អត្តសញ្ញាណ និងការពារជនរងគ្រោះ ស្របជាមួយគោលការណ៍ណែនាំថ្នាក់តំបន់ ។

គោលការណ៍ណែនាំ និងនីតិវិធីកំណត់អត្តសញ្ញាណជនរងគ្រោះ ត្រូវផ្តោតជាសំខាន់នៅក្រោម COMMIT SPA II, ជាពិសេសដោយសារមានការប្រែប្រួលយ៉ាងច្រើននៅក្នុងក្របខ័ណ្ឌច្បាប់ដែលចែងអំពី និងកំណត់និយមន័យការជួញដូរមនុស្សនៅ

ក្នុងតំបន់ មេគង្គ។ រហូតដល់ចុង COMMIT SPA II មានកំណើនការយកចិត្តទុកដាក់លើប្រតិបត្តិការនីតិវិធីពិនិត្យជនរងគ្រោះ និងការកសាងសមត្ថភាពសម្រាប់អាជ្ញាធរពាក់ព័ន្ធនៅជួរមុខនៃកិច្ចការនេះ និងស្ថាប័នដទៃទៀត ដែលទំនងជាត្រូវធ្វើការជាមួយជនរងគ្រោះដោយការជួញដូរ។ ការយកចិត្តទុកដាក់នេះ ត្រូវបានរំពឹងថានឹងបន្តទៅក្នុងដំណាក់កាលអនុវត្ត COMMIT SPA III ជាពិសេស ដោយសារ ការកំណត់អត្តសញ្ញាណជនរងគ្រោះ ភាគច្រើន ជាជំហានដ៏សំខាន់មួយសម្រាប់ទាំងកិច្ចការពារជនរងគ្រោះ និងដើម្បីឱ្យវិធាន ការយុត្តិធម៌ព្រហ្មទណ្ឌ អាចក្លាយជាសកម្មភាពជាក់ស្តែង។COMMIT SPA II ក៏បានវាយតម្លៃផងដែរអំពីប្រសិទ្ធិភាព និងគុណភាពនៃកិច្ចការពារជនរងគ្រោះ និងកម្មវិធីធ្វើសមាហរណកម្មឡើងវិញនៅក្នុងឆ្នាំ 2010 នៅក្នុងការត្រៀមរៀបចំសម្រាប់ COMMIT SPA III។ មេរៀនដែលបានរៀនពីការផ្តួចផ្តើមគំនិតស្រាវជ្រាវថ្នាក់តំបន់ដ៏ទូលំទូលាយ ដោយយកចិត្តទុកដាក់ទៅលើសម្លេងរបស់ជនរងគ្រោះ រួមទាំងកម្មវត្ថុវាស់វែងជាច្រើននៃគុណភាពរបស់ការថែរក្សា ដើម្បីគាំទ្រកម្មវិធីធ្វើសមាហរណកម្មទៅក្នុងសហគមន៍វិញប្រកបដោយប្រសិទ្ធភាព ក្រោម COMMIT SPA III។

សមត្ថភាពរបស់មន្ត្រីការពារជនរងគ្រោះ ក្នុងការអនុវត្តការងាររបស់ពួកគេដោយប្រសិទ្ធិភាព បានកែលម្អយ៉ាងច្រើន នៅក្នុងអំឡុង SPA I និង SPA II ដោយមានការដាក់ឱ្យមានកំណែលម្អជម្រក និងការបណ្តុះបណ្តាលតាមជំនាញឯកទេស។ COMMIT SPA III នឹងកែលម្អជាបន្ថែម ពង្រឹង និងធ្វើឱ្យទៅជាលក្ខណៈស្តង់ដារ នូវការបណ្តុះបណ្តាលឯកទេសនៅថ្នាក់ជាតិ ដោយប្រើប្រាស់គ្រូបង្គាត់ មកពីរដ្ឋាភិបាល និងស្ថាប័នមិនមែនរដ្ឋាភិបាល ដែលជាអ្នកមានវិញ្ញាបនប័ត្របញ្ជាក់។

## ផ្នែក 3: ការពារ ស្តារនីតិសម្បទា និងការធ្វើសមាហរណកម្ម

### សកម្មភាពសម្រាប់ COMMIT SPA III (2011-2013)

| សកម្មភាព | | សេចក្តីអធិប្បាយ |
|---|---|---|
| ★PRO 1<br>ចំណុចដៅ ៣.១ | គោលការណ៍ណែនាំសម្រាប់កំណត់អត្តសញ្ញាណជនរងគ្រោះ និងនីតិវិធីប្រតិបត្តិការស្តង់ដារ (SOPs) | ការបង្កើត និងអនុវត្តគោលការណ៍ណែនាំជាតិស្តីពីការកំណត់អត្តសញ្ញា ណជនរងគ្រោះ ស្របគ្នាជាមួយស្តង់ដារអន្តរជាតិដែលឆ្លើយតបទៅនឹងគ្រប់ទម្រង់នៃការជួញដូរ។ គោលការណ៍ណែនាំទាំងនេះអាចត្រូវបានអនុម័ត នៅក្នុងក្របខ័ណ្ឌ ច្បាប់របស់ជាតិដែលត្រូវបានបង្កើតឡើងដោយមានការ ផ្តល់យោបល់ពីអ្នកធ្វើការងារជាមួយនឹងជនរងគ្រោះ អ្នកកសាងគោលនយោបាយ និងអ្នកទទួលផលនិងត្រូវបានផ្សព្វផ្សាយបានទូលំទូលាយក្នុងចំណោមភ្នាក់ងារដែលបានប្រគល់អណត្តិដើម្បីកំណត់អត្តសញ្ញាណ ជនរងគ្រោះដោយការជួញដូរ ។ មានការប្រាស្រ័យឆ្លើយឆ្លងជាមួយជនរងគ្រោះនៃការជួញដូរត្រូវប្រើ ភាសាកំណើតរបស់ពួកគេ។ |
| PRO 2<br>ចំណុចដៅ ៣.២ | ការពិនិត្យតាមដាន និងរាយការណ៍អំពីការឃុំទុកជនរងគ្រោះពីការជួញដូរ | ការបង្កើត និងអនុវត្តប្រព័ន្ធសម្រាប់រដ្ឋាភិបាល COMMITដើម្បីតាមដាន និងចែករំលែកព័ត៌មានអំពីការឃុំឃាំងជនរងគ្រោះ នៃការជួញដូរដើម្បី ស្វែងរកជំនួយនៅក្នុងករណីដែលជនរងគ្រោះអាចស្ថិតនៅក្រោមការឃុំឃាំង ដើម្បីបង្កើតឱ្យមានការដាក់បណ្តឹង ឬយន្តការរាយការណ៍សម្រាប់កំណត់អត្តសញ្ញាណនិងជួយជនរងគ្រោះនៃការជួញដូរដែលត្រូវស្ថិតក្រោមការឃុំឃាំងនិងដើម្បីពង្រឹងតួនាទីរបស់មន្ត្រីស្ថានទូត នៅក្នុងការជួយជនរងគ្រោះនៃការជួញដូរ ដែលអាចស្ថិតក្រោមការឃុំឃាំង។ |
| ★PRO3<br>ចំណុចដៅ<br>៣.៣ | ការវិលត្រឡប់/មាតុភូមិនិវត្តន៍ និងគោលការណ៍ណែនាំសម្រាប់ការពារជនរងគ្រោះ និងនិងនីតិវិធី ប្រតិបត្តិស្តង់ដារ (SOPs) | ការបង្កើត និងអនុវត្តគោលការណ៍ណែនាំអំពីការវិលត្រឡប់/មាតុភូមិ និវត្តន៍នៃជនរងគ្រោះ ដែលស្របគ្នាជាមួយស្តង់ដារអន្តរជាតិ ហើយឆ្លើយតបទៅនឹងគ្រប់ទម្រង់នៃការជួញដូរ។ គោលការណ៍ណែនាំនានា គួរតែផ្សារភ្ជាប់យ៉ាងច្បាស់លាស់ជាមួយសិទ្ធិនិងកិច្ចការពារ ដែលមានចែង នៅក្នុងច្បាប់ជាតិ ក៏ដូចជា ក្រោមកិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគីដោយមានការសម្របសម្រួលឆ្លងដែន ដើម្បីធានាឱ្យមានមាតុភូមិ និវត្តន៍ជនរងគ្រោះដោយសុវត្ថិភាពទាន់ពេលវេលា។ យន្តការសេវាកម្មគួរ រួមបញ្ចូលប្រព័ន្ធគ្រប់គ្រងករណីបណ្តឹង ដើម្បីសម្របសម្រួលករណីនានា ការផ្តល់ |

| | | |
|---|---|---|
| | | សេវាកម្មគ្រប់ផ្នែកទាំងអស់ ( ដូចជា ការថែទាំនៅតាមស្ថាប័ន ការវិលត្រឡប់មកផ្ទះ ជំនួយខាងវេជ្ជសាស្ត្រ ចិត្តសាស្ត្រ ការអប់រំ/បណ្តុះបណ្តាល ការគាំទ្រដល់របរចិញ្ចឹមជីវិត ជំនួយខាងផ្នែកច្បាប់ ។ល ។) តាមរយៈកម្មវិធីនៅក្នុងនិង/ក្រៅមណ្ឌល ការផ្តល់ឱ្យជនរងគ្រោះនូវឱកាសខាងរបរចិញ្ចឹមជីវិតនៅក្នុងតំបន់គោលដៅ និងការគោរពតាមគោលការណ៍នៃក្រមសីលធម៌ដូចជា កិច្ចការពារទិន្នន័យ រក្សាការសម្ងាត់ ភាពឯកជននិងការយល់ព្រមជាមុន ។ |
| PRO4<br>ចំណុចដៅ ៣.៣ | **គាំទ្រដល់គោលការណ៍ណែនាំសម្រាប់ការអនុវត្ត និងការកសាងសមត្ថភាពសម្រាប់អ្នកគ្រប់គ្រងមណ្ឌល ការថែទាំជំនួសនិងយន្តការបញ្ជូន** | បង្កើត និងអនុវត្តគោលការណ៍ណែនាំសម្រាប់ការពារជនរងគ្រោះ គុណភាពនៃស្តង់ដារថែទាំ ប្រព័ន្ធគ្រប់គ្រងករណី ឧបករណ៍ស្វ័យវាយតម្លៃអំពី ទីជម្រក និងយន្តការបញ្ជូនសេវា ដែលផ្តោតលើអតិថិជន ស្របជាមួយស្តង់ដារអន្តរជាតិ និងឆ្លើយតបទៅនឹងគ្រប់ទម្រង់នៃការជួញដូរ ។ គួរផ្សព្វផ្សាយ គោលការណ៍ណែនាំទាំងនេះដល់ អ្នកធ្វើការងារជាមួយជនរងគ្រោះ ដើម្បីឱ្យពួកគេអនុវត្ត ហើយគោលគារណ៍ទាំងនេះត្រូវបានតាមដាន ជាទៀងទាត់អំពីការគោរពតាម ដោយផ្តោតលើការកសាងសមត្ថភាពឯកទេសដែលចាំបាច់ ។ |
| ★PRO5<br>ចំណុចដៅ ៣.៤ | **ជំនួយការធ្វើសមាហរណកម្ម (ឡើងវិញ) ប្រកបដោយប្រសិទ្ធិភាព** | ការផ្តល់ជំនួយលើសមាហរណកម្មឡើងវិញសម្រាប់រយៈពេលវែងដល់ ជនរងគ្រោះនៃការជួញដូរដើម្បីបំពេញប្រយោជន៍ខ្ពស់បំផុតរបស់ជនរងគ្រោះ សិទ្ធិរបស់ពួកគេនៅក្រោមច្បាប់នៃប្រទេសដើម និងប្រទេសជា គោលដៅ និងដើម្បីគាំទ្រខាងសេដ្ឋកិច្ចនិង/ឬវិជ្ជាជីវៈតាមរយៈការសិក្សាស្រាវជ្រាវអំពីទីផ្សារ ដែលកំណត់អំពីរបរចិញ្ចឹមជីវិតដែលមាននិរន្តរភាព ខាងសេដ្ឋកិច្ចនិងសង្គមនៅក្នុងទីតាំងនៃការធ្វើសមាហរណកម្ម ។ ប្រព័ន្ធសម្រាប់តាមដានប្រសិទ្ធិភាពនៃជំនួយសមាហរណកម្ម នឹងត្រូវផ្អែកលើការឆ្លើយតបរបស់អតិថិជន និងសូចនាករដទៃទៀតអំពីភាពធន់ទ្រាំ និងការផ្តល់សិទ្ធិអំណាចខាងចិត្តសាស្ត្រ និងសេដ្ឋកិច្ច ។ |

| | | |
|---|---|---|
| PRO 6<br>ចំណុចដៅ ៣.៤ | **ការពិនិត្យតាមដានប្រសិទ្ធិភាពនៃការជួយជនរងគ្រោះ និងករណីនៃការរងគ្រោះម្តងទៀតនៃជួញដូរ ឬ ជនរងគ្រោះក្លាយជាឈ្មួញកណ្តាល /អ្នកជួញដូរមនុស្ស** | ការបង្កើត និងអនុវត្តយន្តការតាមដាន និងវាយតម្លៃដែលពិនិត្យមើលប្រសិទ្ធិភាពនៃជំនួយដល់ជនរងគ្រោះ ដោយពិចារណាផងដែរអំពីវិធានការនានា ប្រៀបជាមួយនឹងស្តង់ដារអន្តរជាតិ ក៏ដូចជាយោបល់តបពីអតិថិជនដែលជាជនរងគ្រោះពីការជួញដូរ ។ ការតាមដានក៏នឹងប៉ាន់ ស្មានផងដែរអំពីករណីកើតឡើងនៃការជួញដូរឡើងវិញ និងជនរងគ្រោះ ក្លាយជាអ្នកជួញដូរ និងការរួមញ្ចូលនូវការចែករម្លែកព័ត៌មានរវាង ប្រភព កន្លែងឆ្លងកាត់ និងប្រទេសជាគោលដៅ ។ |
| PRO7<br>ចំណុចដៅ ៣.៥ | **ការបណ្តុះបណ្តាលឯកទេស និងការគាំទ្របច្ចេកទេស សម្រាប់អភិក្រមដែលផ្អែកលើសិទ្ធិ និងតាមបុគ្គលនៅក្នុងកិច្ចការពារនិងគាំទ្រជនរងគ្រោះ** | ផ្តល់ការគាំទ្រផ្នែកបណ្តុះបណ្តាលឯកទេសនិងការគាំទ្របច្ចេកទេសដល់អ្នកផ្តល់សេវាទៅជនរងគ្រោះ ដែលរួមទាំងអ្នកផ្តល់សេវា ជាស្ថាប័នរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល ក៏ដូចជាស្ថានទូត និងអ្នកដទៃទៀតដែលពាក់ព័ន្ធនៅក្នុងការធ្វើមាតុភូមិនិវត្តឆ្លងដែន ដើម្បីបង្កើនប្រសិទ្ធិភាពនៃ ការផ្តល់សេវារបស់ពួកគេ ការគោរពតាមស្តង់ដារគុណភាពអន្តរជាតិនៃ គោលការណ៍ណែនាំអំពីការថែទាំ និងស្តង់ដារក្រមសីលធម៌ និងការពង្រឹងអភិក្រមកុមារមេត្រី និងការកំណត់ឧត្តមប្រយោជន៍របស់ជនរងគ្រោះដែលជាមនុស្សពេញវ័យ និងកុមារ ។ |



# COMMIT SPA III, 2011-2013

# ផ្នែក 4. វិធានការបង្ការទប់ស្កាត់ និងការកាត់បន្ថយភាពងាយរងគ្រោះ

## ផ្នែក4. វិធានការបង្ការទប់ស្កាត់ និងការកាត់បន្ថយភាព ងាយរងគ្រោះ

### គោលបំណងនៅក្នុងអនុស្សរណៈនៃការយោគយល់របស់ COMMIT

| | |
|---|---|
| មាត្រា 22 | ការអនុវត្តវិធានការនានាដើម្បីកាត់បន្ថយភាពងាយរងគ្រោះ ដែលរួមទាំង ការគាំទ្រដល់កម្មវិធីកាត់បន្ថយភាពក្រីក្រ ការបង្កើនឱកាសខាងសេដ្ឋកិច្ច ការធានាលទ្ធភាពទទួលបានការអប់រំ និងការបណ្តុះបណ្តាលជំនាញប្រកបដោយគុណភាព និងការផ្តល់នូវឯកសារច្បាប់ចាំបាច់ផ្ទាល់ខ្លួនដែលរួមទាំង ការចុះបញ្ជីអត្រានុកូលដ្ឋាន។ |
| មាត្រា 23 | ការគាំទ្រដល់ការបង្កើតបណ្តាញការពារសហគមន៍ និងការឃ្លាំមើលសម្រាប់ការកំណត់អត្តសញ្ញាណ និងអន្តរាគមន៍ប្រចាំឆ្នាំអំពីអ្នកដែលប្រឈមនឹងគ្រោះថ្នាក់។ |
| មាត្រា 24 | បង្កើនការយល់ដឹងដល់សាធារណៈនៅគ្រប់កម្រិត ដែលរួមទាំង តាមរយៈយុទ្ធនាការព័ត៌មានសាធារណៈ និងការតស៊ូមតិ ទាំងអំពីគ្រោះថ្នាក់ និងឥទ្ធិពលអវិជ្ជមានអំពីការជួញដូរ និងអំពីជំនួយដែលមានសម្រាប់ជនរងគ្រោះ។ |
| មាត្រា 25 | ការអនុវត្តច្បាប់ការងាររបស់ជាតិ ដើម្បីការពារសិទ្ធិរបស់កម្មករទាំងអស់ ដោយផ្អែកលើគោលការណ៍មិនរើសអើង និងសមភាព។ |
| មាត្រា 26 | ការលើកទឹកចិត្តដល់ប្រទេសជាគោលដៅ ដែលរួមទាំង ប្រទេសនៅក្រៅមហាអនុតំបន់មេគង្គ ឱ្យធ្វើការពង្រឹងការអនុវត្តច្បាប់ដែលពាក់ព័ន្ធឱ្យមានប្រសិទ្ធិភាព ដើម្បីកាត់បន្ថយការទទួលយកនូវការកេងប្រវ័ញ្ចលើមនុស្ស ដែលជម្រុញឱ្យមានតម្រូវការជាបន្តនូវពលករតាមរយៈការជួញដូរមនុស្ស និងឱ្យបង្ក្រាបឧក្រិដ្ឋកម្មនៃការជួញដូរស្ត្រី និងកុមារ តាមរយៈកិច្ចសហប្រតិបត្តិការទៅវិញទៅមក។ |
| មាត្រា 27 | បង្កើនកិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន ជាពិសេស វិស័យទេសចរណ៍ និងឧស្សាហកម្មបម្រើការកំសាន្ត ឱ្យដើរតួនាទីយ៉ាងសំខាន់នៅក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។ |

# ផ្នែក 4: វិធានការបង្ការទប់ស្កាត់ និងការកាត់បន្ថយភាពងាយគ្រោះ

## ចំណុចដៅរបស់ COMMIT SPA III (2011-2013)

| | |
|---|---|
| 4.1 | វិធានការថ្នាក់តំបន់ ជាតិ និង/ឬ នៅមូលដ្ឋានដើម្បីកំណត់ និងកាត់បន្ថយភាពងាយរងគ្រោះនៃការជួញដូរមនុស្ស ត្រូវបានបង្កើតឡើង សាកល្បង ចែករំលែក និងចម្លងទៅអនុវត្តនៅកន្លែងផ្សេងទៀត ក្នុងករណីសមស្រប និងមានប្រសិទ្ធិភាព ខាងការចំណាយ។ |
| 4.2 | បណ្តាញការពារនិងឃ្លាំមើលសហគមន៍ ត្រូវបានបង្កើតឡើង និងពង្រឹង ជាពិសេស នៅក្នុងតំបន់សំខាន់ៗ នៅតំបន់របស់ប្រទេសប្រភព និង ប្រទេសជាគោលដៅ ដើម្បីកំណត់អត្តសញ្ញាណ និងដោះស្រាយតម្រូវការរបស់ប្រជាពលរដ្ឋដែលកំពុងប្រឈមនឹងគ្រោះថ្នាក់។ |
| 4.3 | យុទ្ធនាការលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងយុទ្ធនាការតស៊ូមតិ ដែលលើកឡើងពីការជួញដូរមនុស្ស ការធ្វើអន្តោប្រវេសន៍ដោយសុវត្ថិភាព និងសិទ្ធិពលកម្មត្រូវបានបង្កើតឡើង សាកល្បង និងពង្រីកទៅ អនុវត្តនៅកន្លែងផ្សេង ស្របតាមការវាយតម្លៃផលប៉ះពាល់ជាវិជ្ជមានរបស់គេ អំពីការកែប្រែអាកប្បកិរិយា។ |
| 4.4 | ច្បាប់ការងាររបស់ជាតិ និងគោលនយោបាយពាក់ពន្ធ័ដំទៃត្រូវបានដាក់ឱ្យអនុវត្ត ដើម្បីការពារសិទ្ធិកម្មករទាំងអស់  ដោយផ្អែកលើគោលការណ៍គ្មានការរើសអើង និងសមភាព ដោយមានយន្តការអធិការកិច្ច និងការដាក់ពាក្យបណ្តឹង ដែលមានដំណើរការ សម្រាប់កំណត់អត្តសញ្ញាណ និងដាក់ទណ្ឌកម្មការកេងប្រវ័ញ្ចលើពលករ។ |
| 4.5 | កិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន ត្រូវបានពង្រឹង ដើម្បីពង្រីកតួនាទីសកម្មរបស់ពួកគេក្នុងការ ប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។ ប្រការនេះ អាចរាប់បញ្ចូល ប៉ុន្តែមិនមែនកំហិតត្រឹមជំនួញ និងសមាគមអ្នកជំនួញនៅក្នុងវិស័យទេសចរណ៍ ការដឹកជញ្ជូន ការកំសាន្ត និងឧស្សាហកម្មផ្តោតលើការនាំចេញ ឬវិស័យដទៃទៀត ដែលមានអាណត្តិខាងផ្នែកសង្គមក្នុងការចូលរួមប្រឆាំងការជួញដូរ។ |

### សាវតារ

គោលបំណងរួមនៃផ្នែកនេះគឺ កែលម្អកិច្ចប្រឹងប្រែង ដើម្បីទប់ស្កាត់ការជួញដូរ និងការកេងប្រវ័ញ្ចមនុស្ស កាត់បន្ថយភាពងាយរងគ្រោះនៃការជួញដូរ និងបង្ក្រាបសកម្មភាពឈ្មួញកណ្តាល និង/ឬការងារល្មើសច្បាប់ និង/ឬកេងប្រវ័ញ្ច។ កាលពីអតីតកាល សកម្មភាពទប់ស្កាត់ច្រើនតែប្រមូលផ្តុំលើផ្នែកផ្តត់ផ្គង់    ដោយផ្តោតលើការដោះស្រាយភាពងាយរងគ្រោះនៃសហគមន៍ជាគោលដៅតាមរយៈយុទ្ធនាការបង្កើនការយល់ដឹង ការបណ្តុះបណ្តាលវិជ្ជាជីវៈ មីក្រូឥណទាន ឬ កម្មវិធីនានា ដើម្បីបង្កើនលទ្ធភាពទទួលបានការអប់រំសម្រាប់កុមារដែលងាយរងគ្រោះ។  ក្នុងពេលដែលកិច្ចប្រឹងប្រែងទាំងនេះនៅតែបន្តបង្ហាញពីភាពពាក់ព័ន្ធ  កម្មវិធីផ្សេងទៀត  បានវិវត្តទៅជាការទទួលស្គាល់អំពីភាពជាក់ស្តែងដែលថា  ប្រជាជននឹងបន្តធ្វើចំណាកស្រុក  ដែលជាញឹកញាប់ផ្តល់នូវផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមក  សម្រាប់ប្រទេសអ្នកបញ្ជូន និងប្រទេសអ្នកទទួលពលករ ក៏ដូចជា សម្រាប់បុគ្គលជាពលករផ្ទាល់ផង

ដែរ។ ដូច្នេះ យុទ្ធនាការបង្កើនការយល់ដឹងបានឈានពីគ្រាន់តែផ្តោតលើការកាត់បន្ថយចំណាកស្រុក ទៅរកការកាត់បន្ថយចំណាកស្រុកដែលមានហានិភ័យ ដែលរួមទាំង ចំណាកស្រុកដោយសារតែសេចក្តីអស់សង្ឃឹម។

យុទ្ធសាស្ត្រនានា មានគោលដៅទប់ស្កាត់ការជួញដូរ ត្រូវតែគិតផងដែរអំពីតម្រូវការ ដែលជាមូលហេតុ និងកត្តាផ្សេងទៀតដែលបង្កើនភាពងាយរងគ្រោះនៃការជួញដូរ ដែលរួមទាំងវិសមភាពខាងសេដ្ឋកិច្ច និង/ឬសង្គម និងគ្រប់ទម្រង់នៃការរើសអើង និងការប្រកាន់ពូជសាសន៍។ កិច្ចប្រឹងប្រែងទប់ស្កាត់ការជួញដូរ គួរតែទទួលស្គាល់ផងដែរនូវភាពងាយរងគ្រោះខុសៗគ្នារវាងបុរស និងស្ត្រី ដោយសារតែការងាររវាងភេទទាំងពីរនេះនៅក្នុងឧស្សាហកម្មខុសគ្នា ហើយបុរស និងស្ត្រី ទំនងជាធ្វើចំណាកស្រុក និងធ្វើការសម្រេចចិត្តខុសគ្នា (ដូចជា និន្នាការក្នុងការប្រើប្រាស់ឈ្មួញកណ្តាល និងចំនួនទឹកប្រាក់ដែលបុរស និងស្ត្រីហ៊ានចំណាយលើថ្លៃធ្វើចំណាកស្រុក) និងកត្តាផ្សេងទៀតដែលពាក់ព័ន្ធខាងយេនឌ័រ។ យុទ្ធសាស្ត្រទប់ស្កាត់ដែលមានប្រសិទ្ធិភាព ត្រូវតែផ្អែកលើបទពិសោធន៍ ដែលមានស្រាប់ និងទិន្នន័យសុក្រឹត្យដែលជាក់លាក់ទៅតាមកន្លែងនីមួយៗនៃភាពងាយរងគ្រោះ និងគួរតែកើតឡើងនៅឯប្រភព គោលដៅ ក្នុងពេលឆ្លងកាត់ និងពេលឆ្លងដែន។

# ផ្នែក 4: វិធានការបង្ការទប់ស្កាត់ និងការកាត់បន្ថយភាពងាយរងគ្រោះ

## សកម្មភាព COMMIT SPA III (2011-2013)

| សកម្មភាព | | សេចក្តីអធិប្បាយ |
|---|---|---|
| ★PRE1<br>ចំណុចដៅ<br>៤.១ | កិច្ចផ្តួចផ្តើមកាត់បន្ថយភាពងាយរងគ្រោះ | គាំទ្រដល់កិច្ចផ្តួចផ្តើមដែលផ្អែកលើការពិសោធន៏ ដើម្បីផ្តោតលើ និងកាត់បន្ថយភាពងាយរងគ្រោះនៃការជួញដូរ ការកេងប្រវ័ញ្ច និង ការធ្វើចំណាកស្រុកគ្មានសុវត្ថិភាព ដែលរួមទាំង សកម្មភាពពង្រឹងសិទ្ធិខាងសេដ្ឋកិច្ច ដើម្បីជម្រុញជម្រើសជំនួសនៃការចិញ្ចឹមជីវិតដែលមាននិរន្តរភាព ជាជាងការធ្វើចំណាកស្រុកដែលគ្មានសុវត្ថិភាព។ ការផ្តោតលើបង្កើនការយល់ដឹង ដែលរួមទាំងព័ត៌មានអំពីចំណាកស្រុកដែលមានសុវត្ថិភាព និងសិទ្ធិការងារ និង ការផ្តល់ឯកសារច្បាប់ចាំបាច់ផ្ទាល់ខ្លួន ដែលរួមទាំង ការចុះបញ្ជីកំណើត។ |
| PRE 2<br>ចំណុចដៅ<br>៤.២ | ប្រព័ន្ធការពារសហគមន៍ និងឃ្លាំមើលនៅតាមព្រំដែន | គាំទ្រដល់ប្រព័ន្ធការពារសហគមន៏ និងតំបន់តាមព្រំដែន និងប្រព័ន្ធឃ្លាំមើល ដើម្បីផ្តោតលើសហគមន៏ដែលងាយរងគ្រោះ និងក្រុមប្រឈមនឹងគ្រោះថ្នាក់នៅថ្នាក់ជាតិ និងមូលដ្ឋាន ដែលរួមទាំងការកសាងសមត្ថភាពរបស់អ្នកឆ្លើយតបនៅជួរមុខ និងក្រុមឃ្លាំមើល នៅក្នុងប្រព័ន្ធឃ្លាំមើល និងការផ្សព្វផ្សាយអំពីចំណាកស្រុកដែលមានសុវត្ថិភាព និងសេវាកម្មដែលពាក់ព័ន្ធសម្រាប់អ្នកដែលរងការជួញដូរ ឬ កេងប្រវ័ញ្ច ព្រមទាំងភ្ជាប់ទំនាក់ទំនងប្រព័ន្ធនៅមូលដ្ឋានទាំងនេះជាមួយអង្គភាពរដ្ឋាភិបាលដែលពាក់ព័ន្ធ។ |
| PRE 3<br>ចំណុចដៅ<br>៤.៣ | ការលើកកម្ពស់យល់ដឹងជាសាធារណៈ | បង្កើនការយល់ដឹងជាសាធារណៈអំពីការជួញដូរមនុស្ស និងចំណាកស្រុកដែលមានសុវត្ថិភាព តាមរយៈប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន អ្នកសារព័ត៌មាន កិច្ចប្រជុំ សហគមន៏ ការផ្សព្វផ្សាយរវាងក្រុមមិត្តអប់រំមិត្ត ការប្រគុំតន្ត្រី បាឋកថា ការបណ្តុះបណ្តាល ការសំដែងតាមដងផ្លូវ ភាពយន្តឯកសារ សិល្បៈកំប្លែង ឬ មធ្យោបាយផ្សេងទៀតដែលសមស្របជាមួយក្រុមមនុស្សជាគោលដៅ។ |
| ★PRE4<br>ចំណុចដៅ<br>៤.៤ | ពង្រឹងយន្តការការពារពលកម្មប្រឆាំងការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការជួញដូរតាមរយៈការរៀបអាពាហ៍ពិពាហ៍ | គាំទ្រឱ្យមានការពង្រឹងបន្ថែមទៀតលើការអនុវត្តច្បាប់ការងាររបស់ជាតិ ដើម្បីការពារសិទ្ធិកម្មករ តាមរយៈវិធានការនានា ដើម្បីចាត់ចែងបានប្រសើរ ជាងមុននូវដំណើរការរើសពលករ ការតាមដាននៃការអនុវត្តអធិការកិច្ច ការងារ និងការពង្រឹងចំណងទាក់ទងរវាង |

| | | |
|---|---|---|
| | | មន្ត្រីអធិការកិច្ចការងារនិង ទីភ្នាក់ងារពង្រឹងការអនុវត្តច្បាប់ ការតាមដានលើការរៀបការតាមរយៈ ឈ្មួញកណ្តាល និងទីភ្នាក់ងារសុំកូនចិញ្ចឹម ការកសាងសមត្ថភាពមន្ត្រីអនុព័ន្ធការងារ និងមន្ត្រីស្ថានកុងស៊ុលនិងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរនៃប្រទេសជាម្ចាស់ផ្ទះ សហគមន៍ជន ចំណាកស្រុក និងនិយោជក ក្នុងការ គាំទ្រជនដែលរងគ្រោះដោយការជួញដូរទាំងតាមរយៈកម្លាំងពលកម្ម និងការរៀបការ ។ ការផ្សព្វផ្សាយព័តិមានអំពីសិទ្ធិការងារជាភាសា ដែលពាក់ព័ន្ធដែលរួមទាំង ការផ្តល់អាស័យដ្ឋានទាក់ទងរបស់អ្នកផ្តល់សេវា ក្នុងមូលដ្ឋាន នៅពេលមានករណីបន្ទាន់ និងគាំទ្រតាមរយៈទូរស័ព្ទ និងសេវាបន្ទាន់សម្រាប់ការពារជនចំណាកស្រុក ។ |
| PRE 5<br>ចំណុចដៅ<br>៤.៤ | ពង្រឹងតួនាទី និងសមត្ថភាពរបស់មន្ត្រីមិនមែនជាប៉ូលីស ក្នុងការ ពង្រឹងការអនុវត្តច្បាប់ ដើម្បីកាត់បន្ថយការកេងប្រវ័ញ្ច | គាំទ្រការស៊ូមតិ ការបណ្តុះបណ្តាល និងបណ្តាញ សម្រាប់មន្ត្រីមិនមែនគរបាល ឧទាហរណ៏មន្ត្រីការងារ ដើម្បីលើកទឹកចិត្តដល់អ្នកពាក់ព័ន្ធសំខាន់ៗ នៅក្នុងប្រទេសជាគោលដៅ ដោយផ្តោតលើនិយោជកដែលកេងប្រវ័ញ្ច និងពង្រឹងការអនុវត្តច្បាប់ព្រហ្មទណ្ឌ និងច្បាប់ការងារ ដើម្បីទប់ស្កាត់ និងកាត់បន្ថយការកេងប្រវ័ញ្ចមនិងការជួញដូរមនុស្ស ។ |
| PRE 6<br>ចំណុចដៅ<br>៤.៥ | កិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន និងការធ្វើឱ្យក្រុមហ៊ុនមានការទទួលខុសត្រូវខាងសង្គម | បង្កើនកិច្ចប្រឹងប្រែងដើម្បីធ្វើឱ្យវិស័យឯកជនចូលរួមនៅក្នុងការប្រយុទ្ធ ប្រឆាំងការជួញដូរមនុស្ស តាមរយៈការតស៊ូមតិ ការផ្សព្វផ្សាយ និងការចូល រួមនៅក្នុងកិច្ចផ្តួចផ្តើមភាពជាដៃគូសាធារណៈ-ឯកជន ព្រមទាំងការជម្រុញ ឱ្យអាជីវកម្មនានាគោរពតាមក្រមសីលធមិ  និងបង្កើតឱ្យមានការទទួលខុស ត្រូវខាងសង្គមរបស់សារជីវកម្ម នៅក្នុងវិស័យនានា ដែលមានកិច្ចការស្ទួល និង/ឬ អាណត្តិខាងសង្គមដែលទាក់ទងនឹងការប្រឆាំងនឹងការជួញដូរមនុស្ស ។ |

# COMMIT SPA III, 2011-2013

# ផ្នែក 5. ប្រព័ន្ធពិនិត្យតាមដាន វាយតម្លៃ និងប្រមូលចងក្រងទិន្នន័យ សម្រាប់ការងារប្រឆាំងនឹង ការជួញដូរមនុស្ស

# ផ្នែក 5. ប្រព័ន្ធពិនិត្យតាមដាន វាយតម្លៃ និងប្រមូលចងក្រងទិន្នន័យសម្រាប់ការងារប្រឆាំងការជួញដូរមនុស្ស

| គោលបំណងនៅក្នុងអនុស្សរណៈនៃការយោគយល់របស់ COMMIT | |
|---|---|
| មាត្រា 29 | ការប្រមូល និងវិភាគទិន្នន័យ និងព័ត៌មានអំពីករណីជួញដូរ ដែលធានាថា យុទ្ធសាស្ត្រប្រឆាំងការជួញដូរមនុស្ស បានផ្អែកលើការស្រាវជ្រាវ បទពិសោធន៍ និងការវិភាគសុក្រឹត្យនិងថ្មីៗ ។ |
| មាត្រា 30 | ការបង្កើតប្រព័ន្ធតាមដានមួយសម្រាប់អនុវត្តផែនការសកម្មភាព ដើម្បីវាយតម្លៃស្ថានភាពបច្ចុប្បន្ន និងការរីកចម្រើននៅក្នុងប្រទេសនីមួយៗ នៅក្នុងការអនុវត្តការប្តេជ្ញានានាដែលមានចែងនៅក្នុងអនុស្សរណៈនេះ ។ |

## ផ្នែក 5: ប្រព័ន្ធពិនិត្យតាមដាន វាយតម្លៃ និងប្រមូលចងក្រងទិន្នន័យសម្រាប់ការងារប្រឆាំងការជួញដូរមនុស្ស

### ចំណុចដៅសម្រាប់ផែនការសកម្មភាព COMMIT SPA III (2011-2013)

| | |
|---|---|
| 5.1 | ប្រព័ន្ធទិន្នន័យដែលប្រមូលជំពូកទិន្នន័យសំខាន់ៗអំពីការជួញដូរមនុស្សត្រូវបានបង្កើតឡើងដាក់ឱ្យដំណើរការ និងបានទទួលការគាំទ្រតាមរយៈអាណត្តិ និងថវិការបស់រដ្ឋាភិបាល ។ |
| 5.2 | ការងារប្រឆាំងអំពើរជួញដូរមនុស្សត្រូវបានពង្រឹងដោយការស្រាវជ្រាវ និងការវិភាគ ដែលរួមទាំងការកំណត់អត្តសញ្ញាណ កត្តាដែលនាំឱ្យមានភាពងាយរងគ្រោះ បែបបទនៃប្រតិបត្តិការ នៃអ្នកជួញដូរ និងប្រសិទ្ធិភាពនៃច្បាប់គោលនយោបាយ និងវិធានការ នានាប្រឆាំងការជួញដូរ ។ |
| 5.3 | របាយការណ៍ពិនិត្យតាមដានប្រចាំឆ្នាំ និងការវាយតម្លៃចុងក្រោយអំពីការរីកចម្រើននៃរដ្ឋាភិបាល COMMIT លើចំណុចដៅ និងគោលដៅនានាដែលបានឯកភាពគ្នា នៅក្នុង COMMIT SPA III (2011-2013) ត្រូវបានបោះពុម្ពផ្សាយ ។ |
| 5.4 | ការវាយតម្លៃផលប៉ះពាល់នៅក្រោម COMMIT SPA III ដែលវាស់ឥទ្ធិពលពីកិច្ចប្រឹងប្រែងពហុទីភ្នាក់ងារលើការទប់ស្កាត់ កិច្ចការពារ និងនាំផ្តន្ទាទោស នៅទូទាំងតំបន់មេគង្គ ត្រូវបានអនុវត្តរួចរាល់ នៅក្នុងរយៈពេលមួយឆ្នាំនៃការបញ្ចប់ COMMIT SPA III ។ |

## សាវតារ

ប្រភេទទិន្នន័យមួយចំនួនមានសារៈសំខាន់ណាស់ ដើម្បីវាស់ឥទ្ធិពល/ផលប៉ះពាល់នៃកិច្ចប្រឹងប្រែងប្រឆាំងការជួញដូរ (ដែលរួមទាំង គោលនយោបាយ ការទប់ស្កាត់ ការនាំជនល្មើសមកកាត់ទោស និងកិច្ចការពារជនរងគ្រោះ) ។ ដើម្បីតាមដានទិន្នាការនៃការជួញដូរមនុស្ស គេគួរតែប្រមូលទិន្នន័យនេះ ដោយប្រើប្រាស់វិធីសាស្ត្រប្រហែលគ្នានេះនៅក្នុងទីតាំងមួយចំនួន និងតាមកម្មវិធីជាទៀងទាត់។ COMMIT SPA III មានគោលដៅបង្កើតប្រព័ន្ធទិន្នន័យនៅថ្នាក់ជាតិនិងនៅទូទាំងតំបន់ ដែលប្រមូល និងវិភាគជំពូកទិន្នន័យទាំងនោះ ក្នុងគោលដៅពង្រឹងមូលដ្ឋាននៃការសិក្សាដកស្រង់បទពិសោធន៍អំពីវិធានការប្រឆាំងការជួញដូរមនុស្ស។

1. **ឧទាហរណ៍ទី១ : ទិន្នន័យអំពីជនរងគ្រោះ និងកត្តាងាយរងគ្រោះរបស់ជនរងគ្រោះ** : ទិន្នន័យនេះប្រមូលបានមកពីការសម្ភាសន៍ជា មួយជនរងគ្រោះនានាពីការជួញដូរ អាចយកទៅប្រៀបធៀបជាមួយរឿងរ៉ាវរបស់ជនមិនមែនជាអ្នករងគ្រោះ ដើម្បី ប្រៀបធៀបអំពី ស្ថានភាពគ្រួសារ សហគមន៍ និងការងារ និងស្វែងយល់អំពីកត្តាហានិភ័យនៃការជួញដូរ និងកត្តាការពារ ដែលអាចជួយទប់ស្កាត់មិនឱ្យមានការជួញដូរ។ ប្រភពទិន្នន័យអាចរាប់បញ្ចូល :
   - **សហគមន៍មានបញ្ហាជួញដូរមនុស្ស នៅកន្លែងជាប្រភពដើម** : ដើម្បីប្រៀបធៀបស្ថានភាពនានារបស់ប្រជាពលរដ្ឋដែលបាន ទទួលជោគជ័យក្នុងការធ្វើចំណាកស្រុក អ្នកដែលមិនទទួលជោគជ័យ (ពោលគឺ ជនរងគ្រោះពីការជួញដូរ), និងអ្នក ដែលមិនធ្លាប់ធ្វើចំណាកស្រុក។
   - **សហគមន៍មានបញ្ហាជួញដូរមនុស្ស នៅកន្លែងទទួល** : ដើម្បីពិនិត្យមើល និងប្រៀបធៀបបទពិសោធន៍នានារបស់កម្មករចំណាកស្រុកដែលមិនរងការកេងប្រវ័ញ្ច និងកម្មករចំណាកស្រុកដែលរងការកេងប្រវ័ញ្ច។
   - **ក្រុមគោលដៅនៅក្នុងពេលឆ្លងកាត់** ឧទាហរណ៍ក្រុមជនដែលត្រូវបានគេនិរទេស ដើម្បីប្រៀបធៀបនឹងបទពិសោធន៍ អំពីករណីមិនរងការជួញដូរ ធៀបនឹងការជួញដូរ ស្រដៀងគ្នានឹងករណីខាងលើ។
2. **ឧទាហរណ៍ទី២ : ទិន្នន័យអំពីឧក្រិដ្ឋជន និងបណ្តាញរបស់ពួកគេ និងរបៀបប្រតិបត្តិការ** : ទិន្នន័យនេះអាចប្រមូលបានពីប្រភព សំខាន់ៗចំនួនបី និងគួរតែពិនិត្យឡើងវិញ រវាងប្រភពនានា ដើម្បីបង្កើនទំនុកចិត្ត និងភាពត្រឹមត្រូវ។
   - **ជនរងគ្រោះនៃការជួញដូរ និងកម្មករចំណាកស្រុក** ប្រសិនបើពួកគេយល់ព្រមបង្ហាញឱ្យដឹងលំអិតអំពី ការជួញដូរពួកគេ និងអំពីឧក្រិដ្ឋជន ដែលបានបោកប្រាស់ និងកេងប្រវ័ញ្ចលើពួកគេ។
   - **អង្គការមិនមែនរដ្ឋាភិបាល** ដែលអាចធ្វើការខាងផ្នែកសិទ្ធិមនុស្ស ឬ ផ្តល់សេវាកម្មចំណាកស្រុកនៅក្នុងសហគមន៍ដែលមានបញ្ហាជួញដូរច្រើន។
   - **មន្ត្រីអនុវត្តច្បាប់** ដែលអាចទទួលផលពីការទទួលបាន និងការចែករំលែព័ត៌មានរវាងអង្គភាពស៊ើបអង្កេត និងជាមួយអង្គការក្រៅរដ្ឋាភិបាល ដែលពាក់ព័ន្ធ។ នគរបាលអាចមិនបញ្ចេញឱ្យដឹងពតិមានអំពីករណីនានា ដែលអាចធ្វើឱ្យខូចការស៊ើបអង្កេតរបស់ពួកគេហើយអង្គការក្រៅរដ្ឋាភិបាលអាចមិនបញ្ចេញពតិមានលំអិតអំពីករណីរបស់ជនរង គ្រោះដែលមិនយល់ព្រមឱ្យចែករំលែកព័តិមានអំពីខ្លួនគេជាមួយនគរបាល ប៉ុន្តែជាទូទៅការចែករំលែកព័តិមានរវាង នគរបាល និងអង្គការក្រៅរដ្ឋាភិបាល ជាញឹកញាប់អាចផ្តល់ផលវិជ្ជមាន។
3. **ឧទាហរណ៍ទី ៣ : ទិន្នន័យអំពីប្រសិទ្ធិភាពនៃការអនុវត្តច្បាប់ គោលនយោបាយ និងវិធានការនានា** : ជាការប្រសើរបំផុត ទិន្នន័យនេះ គួរតែប្រមូលបានពីអ្នកទទួលផលពីច្បាប់ និងប្រព័ន្ធទាំងនេះ ដើម្បីចង់ដឹងថាតើ ភាពប្រសើរនៅក្នុងគោលនយោបាយច្បាប់ និងការកសាងសមត្ថភាពសម្រាប់អ្នកឆ្លើយតបក្នុងការប្រឆាំងការជួញដូរមនុស្ស ពិតជានាំទៅរកការធ្វើឱ្យមានភាពខុសគ្នាជាវិជ្ជមាន ក្នុងការរស់នៅរបស់ប្រជាជនដែលរងគ្រោះ ដោយសារការជួញដូរមនុស្ស និងការគោរពសិទ្ធិមនុស្ស ដូច្នេះ ជាព័តិមាននេះទទួលបានពីជនរងគ្រោះនៃការជួញដូរ ឬក្រុមពលរដ្ឋដែលងាយរងគ្រោះ។ លើសពីនេះ តារាងព័តិមានរបស់រដ្ឋាភិបាលនិងអង្គការមិនមែនរដ្ឋាភិបាលដែលពិនិត្យមើលប្រសិទ្ធិភាពនៃប្រព័ន្ធនានា អាចមានប្រយោជន៍ ឧទា

ហរណ៏ កំណើនចំនួនជនរងគ្រោះដែលបានធ្វើអត្តសញ្ញាណ/ដែលបានជួយនៅក្នុងតំបន់ជាគោលដៅ សម្រាប់ការអនុម័តច្បាប់ ឬ គោលនយោបាយថ្មីៗ ឬ ការកសាងសមត្ថភាពរបស់មន្ត្រីពាក់ព័ន្ធនៅក្នុងតំបន់នោះ។

# ផ្នែក 5: ប្រព័ន្ធពិនិត្យតាមដាន ការវាយតម្លៃ និងប្រមូលចងក្រងទិន្នន័យសម្រាប់ការងារប្រឆាំងការជួញដូរមនុស្ស

## សកម្មភាព COMMIT SPA III (2011-2013)

| សកម្មភាព | | សេចក្តីអធិប្បាយ |
|---|---|---|
| M&E1<br>ចំណុចដៅ<br>៥.១ | ការកសាងប្រព័ន្ធទិន្នន័យ និងសមត្ថភាព ប្រឆាំងការជួញដូរមនុស្ស | ការបង្កើតហេដ្ឋារចនាសម្ព័ន្ធ និងពង្រឹងសមត្ថភាពសម្រាប់ប្រព័ន្ធតាមដានទិន្នន័យប្រឆាំងការជួញដូរមនុស្សនៅថ្នាក់ជាតិ និងតំបន់ ដោយមានការប្តេជ្ញាចិត្ត ដើម្បីធ្វើការឆ្លោះទៅរកវេទិកាចែករំលែកព័ត៌មានស្របគ្នា នៅថ្នាក់ជាតិ និងថ្នាក់តំបន់។ |
| M&E2<br>ចំណុចដៅ<br>៥.១ | ការរៀបចំចងក្រងស្ថិតិផ្លូវការ | ការប្រមូល ការវិភាគ និងការចែករំលែកស្ថិតិផ្លូវការស្តីពីការឃាត់ខ្លួន ការផ្តន្ទាទោស ការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះដែលបានជួយ ។ល។ ដើម្បីផ្តល់នូវបរិបទស្តីពីភាពខ្លាំង និងផ្តោតលើការឆ្លើយតបប្រឆាំងនឹងការជួញដូរមនុស្ស។ |
| M&E3<br>ចំណុចដៅ<br>៥.២ | ការស្រាវស្រាវស្តីពីចំនួន ផ្លូវឆ្លងកាត់ ទម្រង់នៃ និងនិន្នាការនៃការជួញដូរមនុស្ស | ការបង្កើត និងពង្រឹងប្រព័ន្ធស្រាវជ្រាវ ដើម្បីវាស់ចំនួនករណី និងទម្រង់នៃការជួញដូរ ដែលរួមទាំងការសម្ភាសន៍ជាមួយជនចំណាកស្រុកដែលមិន រងការកេងប្រវ័ញ្ច និងអ្នកដែលរងការកេងប្រវ័ញ្ច ដើម្បីប្រមូលព័ត៌មាន អំពីកត្តាងាយរងគ្រោះរបស់ជនរងគ្រោះ បណ្តាញឧក្រិដ្ឋកម្ម ឧស្សាហកម្ម ដែលកេងប្រវ័ញ្ចពលកម្មជាងគេ និងប្រសិទ្ធិភាពនៃការធ្វើអត្តសញ្ញាណជនរងគ្រោះ និងការស៊ើបអង្កេតឧក្រិដ្ឋជននៃករណីជួញដូរ។ |
| M&E4<br>ចំណុចដៅ<br>៥.៣ និង<br>៥.៤ | ការពិនិត្យតាមដាន វាយតម្លៃ និងរាយ ការណ៍សម្រាប់ខមមីត | ការតាមដាន ការវាយតម្លៃ និងការរាយការណ៍ជាលក្ខណៈស្តង់ដារ អំពីសកម្មភាពនានា និងលទ្ធផលសំខាន់ៗ របស់រដ្ឋាភិបាល COMMIT នៅក្រោម COMMIT SPA III ធៀបនឹងចំណុចដៅ និងគោលដៅនៅក្នុង COMMIT SPA III។ កិច្ចការនេះ រួមបញ្ចូលការតាមដានវិភាជន៍ថវិការបស់ខមមីតសម្រាប់វិធានការប្រឆាំងការជួញដូរមនុស្ស ជំហរ និងសកម្មភាពនានា ដើម្បីពង្រឹងនិរន្តរភាព និងភាពជាម្ចាស់។ គារវាយតម្លៃផលប៉ះពាល់នានា នៅចុង COMMIT SPA III នឹងជួយវាស់ផលប៉ះពាល់នៃសកម្មភាព COMMIT មកលើស្ថានភាពជួញដូរមនុស្ស និងមកលើប្រជាពលរដ្ឋ និងក្រុមមនុស្សដែលរងគ្រោះពីការជួញដូរ។ |

# តារាងសង្ខេបចំណុចដៅនិងសកម្មភាពទាំងអស់របស់

# COMMIT SPA III

# តារាងសង្ខេបសកម្មភាពនិងចំណុចដៅទាំងអស់របស់ COMMIT SPA III

ដូចបានបញ្ជាក់ក្នុងទំព័រលេខ ៦? ។ នៅក្នុងផ្នែកនីមួយៗ សកម្មភាពដែលដោយរដ្ឋាភិបាលយល់ព្រមជាសកម្មភាពអធិភាពត្រូវបានសម្គាល់ដោយសញ្ញា '★' ហើយរាល់រដ្ឋាភិបាលទាំង អស់ត្រូវបានលើកទឹកចិត្តឱ្យសកម្មភាពទាំងនោះក្នុងកំឡុងពេលនៃ COMMIT SPA III ។ ចំណែកឯសកម្មភាពដ៏ទៃទៀតទាំងអស់ត្រូវបានរដ្ឋាភិបាល COMMIT យល់ព្រមលើកយកមកបង្ហាញ ដោយអាស្រ័យទៅនឹងតំរូវការ និងអាទិភាពផ្សេងៗរបស់ប្រទេស នីមួយៗ ។

| ផ្នែក 1: គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ | | |
|---|---|---|
| | **សកម្មភាព** | **ចំណុចដៅ** |
| ★P&C1 | គាំទ្រផែនការសកម្មភាពជាតិប្រឆាំងនឹងអំពើជួញដូរមនុស្ស | **១.១** ផែនការសកម្មភាពជាតិ (ធ្វើឱ្យស្របតាម COMMIT MOU តាមដែលអាចធ្វើបាន) ត្រូវបានអនុម័ត ដែលដោះស្រាយគ្រប់ទម្រង់នៃការជួញដូរ ដោយមានប្រព័ន្ធនានា ដំណើរការ ដើម្បីតាមដាន និងរាយ ការណ៏អំពីការរីកចម្រើន និងលទ្ធផលយ៉ាងទៀងទាត់ នៅខណៈពេលដែលកំណើនថវិការរដ្ឋាភិបាល ដែលបានផ្តល់ប្រចាំឆ្នាំសំរាប់ការគាំទ្រដល់ជំហរ ពិធី យន្តការ ការប្រជុំ និងការចំណាយដ៏ទៃទៀត ។ ប្រពន្ធ័ទាំងនោះរួមមានគណៈកម្មាធិការ រឺក្រុមការងារ ពហុវិស័យ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។<br>**១.២** កម្មវិធីបណ្តុះបណ្តាលទូលំទូលាយនៅជាតិនិងថ្នាក់តំបន់ ត្រូវបានរៀបចំឡើងសម្រាប់អ្នកឆ្លើយតប និងអ្នកតាក់តែងគោលនយោបាយ នៅក្នុងរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ហើយកម្មវិធី បណ្តុះបណ្តាលនេះត្រូវរៀបចំដោយក្រុមគ្រូថ្នាក់ជាតិឬថ្នាក់តំបន់ ។ |
| ★P&C2 | ការបណ្តុះបណ្តាល និងកសាងសមត្ថភាពសម្រាប់អ្នកឆ្លើយតប និងអ្នកកសាង គោលនយោបាយនៅថ្នាក់ជាតិ | |
| P&C3 | អនុវត្តកិច្ចព្រមព្រៀងឆ្លងដែន ដែលរួមទាំង | |

| | | |
|---|---|---|
| | ការបង្កើត និងអនុវត្តន៍ វិធីប្រតិបត្តិការស្តង់ដារ (SOPs | **១.៣** កិច្ចព្រមព្រៀងឆ្លងដែន ត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការនិងតាមដានតាមទីកន្លែងដែលលំហូរការជួញដូរ បង្ហាញអំពីតម្រូវការ ជាអាទិភាពឱ្យមានយន្តការនានា។ ផែនការសកម្មភាព និងនីតិវិធីប្រតិបត្តិការ ត្រូវបានដាក់ឱ្យអនុវត្ត ហើយផែនការអនុវត្ត ត្រូវបានពិនិត្យប្រចាំឆ្នាំ ។ |
| P&C4 | គាំទ្រដល់កិច្ចសហប្រតិបត្តិការជាមួយនឹងប្រទេសក្រៅពីតំបន់ COMMIT | **១.៤** កិច្ចសហប្រតិបត្តិការប្រឆាំងការជួញដូរមនុស្ស ជាមួយប្រទេសនានា និងស្ថាប័នពហុភាគី នៅខាងក្រៅ តំបន់ COMMIT ត្រូវបានអនុវត្ត។<br>**១.៥** កិច្ចសហប្រតិបត្តិការឆ្លងដែនប្រកបដោយប្រសិទ្ធិភាព បានទទួលការគាំទ្រ និង គូសបញ្ជាក់ដោយយន្តការ ដែលមានដំណើរការ សម្រាប់ការប្រមូល វិភាគ និងផ្លាស់ប្តូរព័ត៌មានប្រកបដោយប្រសិទ្ធិភាព រវាងក្រសួងនៃរដ្ឋាភិបាល និងសាធារណៈជន។ |
| P&C5 | ការផ្លាស់ប្តូរព័ត៌មានឆ្លងដែន | |
| P&C 6 | ការចូលរួម និងការពិគ្រោះយោបល់ជាមួយបុគ្គលនានាដែលរងគ្រោះដោយការជួញដូរមនុស្ស | **១.៦** បុគ្គលទាំងឡាយណាដែលរងគ្រោះដោយអំពើរជួញដូរមនុស្សដែលរួមមានជនរងគ្រោះនៃការជួញដូរត្រូវបានឱ្យចូលរួម និងផ្តល់អនុសាសន៍លើការងារពិនិត្យតាមដាន និងវាយតម្លៃនៃភាពលើប្រសិទ្ធភាពនៃ កម្មវិធីប្រឆាំងការជួញដូរមនុស្ស នៅថ្នាក់ជាតិ។ |

<table>
<tr><th colspan="3">ផ្នែក 2. ក្របខ័ណ្ឌច្បាប់  ការអនុវត្តច្បាប់  និងយុត្តិធម៌</th></tr>
<tr><th colspan="2">សកម្មភាព</th><th>ចំណុចដៅ</th></tr>
<tr><td>★CJ1</td><td>ច្បាប់ស្តីពីការជួញដូរមនុស្ស ដោយប្រើប្រាស់និយមន័យអន្តរជាតិអំពីការជួញដូរមនុស្ស និងការអនុវត្តច្បាប់ព្រហ្ម ទណ្ឌ ដទៃទៀតប្រឆាំងអ្នកជួញដូរមនុស្ស</td><td rowspan="5">២.១ ច្បាប់ទូលំទូលាយស្តីពីការជួញដូរមនុស្ស ស្របជាមួយនិយមន័យអន្តរជាតិ ត្រូវបានចូលជាធរមាន និង ដាក់ឱ្យអនុវត្តពេញលេញ ។ ច្បាប់ពាក់ព័ន្ធផ្សេងទៀត ក៏អាចអនុវត្តបានផងដែរ នៅក្នុងករណីនៃការ ជួញដូរមនុស្ស ហើយអ្នកស៊ើបអង្កេតគួរពិចារណាលើគ្រប់ រូបភាពនៃបទល្មើសដែលបានប្រព្រឹត្ត ។<br>២.២ មន្ត្រីអនុវត្តច្បាប់បានទទួលការបណ្តុះបណ្តាលសមស្រប និងប្រតិបត្តិការ ទៅតាមមុខនាទីរបស់ខ្លួន ដែលរួមទាំងអង្គភាពឯកទេសប្រឆាំងការជួញដូរមនុស្ស និងនគរបាល ដែលអនុវត្តមុខនាទីទូទៅ និងមន្ត្រីអន្តោប្រវេសន៍នៅក្នុងតំបន់ ដែលមានការជួញដូរច្រើន ។ ការបណ្តុះបណ្តាលត្រូវបញ្ចូល ការកំណត់អត្តសញ្ញាណជនរងគ្រោះ និងបច្ចេកទេសនៃការស៊ើបអង្កេតករណីជួញដូរ ព្រមទាំងមាន ការស៊ើបអង្កេត និងការដាក់ទណ្ឌកម្ម លើការឃុបឃិត និងអំពើពុករលួយនៅក្នុងការអនុវត្តច្បាប់ ។<br>២.៣ អ្នកស៊ើបអង្កេតនិងព្រះរាជអាជ្ញាដែលបានពាក់ព័ន្ធនៅក្នុងការឆ្លើយតបខាងយុត្តិធម៌ព្រហ្មទណ្ឌប្រឆាំង ការជួញដូរមនុស្ស បានទទួលការបណ្តុះបណ្តាលអំពីទិដ្ឋភាពបច្ចេកទេសដែលពាក់ព័ន្ធជាមួយឧក្រិដ្ឋកម្ម ដោយមានការគាំទ្រដល់កិច្ចសហប្រតិបត្តិ ការពហុវិស័យ យន្តការកសាងសមត្ថភាពរួមគ្នា និងបណ្តាញ មន្ត្រីអនុវត្តច្បាប់ព្រះរាជអាជ្ញា និងចៅក្រម ។<br>២.៤ គាំទ្រដល់ការបង្កើនគុណភាពដែលអាចវាស់បានចំពោះការឆ្លើយតបនៃយុត្តិធម៌ព្រហ្មទណ្ឌប្រឆាំងការ ជួញដូរមនុស្ស ដែលរួមមាន (ក)ការធ្វើសមាហរណកម្មបានប្រសើរជាងមុន ដោយមានការឆ្លើយតប ខាងផ្នែកសេវា</td></tr>
<tr><td>CJ2</td><td>ពង្រឹងអង្គភាពឯកទេសផ្នែកអនុវត្តច្បាប់ប្រឆាំងការជួញដូរមនុស្ស</td></tr>
<tr><td>CJ3</td><td>ការស៊ើបអង្កេតបុរេសកម្ម</td></tr>
<tr><td>★CJ4</td><td>ពង្រឹងការសម្របសម្រួលការឆ្លើយតប ខាងព្រហ្មទណ្ឌយុត្តិធម៌ជាមួយការពារជនរងគ្រោះ</td></tr>
<tr><td>CJ5</td><td>ការបណ្តុះបណ្តាលឯកទេសជំនាញ និងការបណ្តាញសម្រាប់ទីភ្នាក់ងារព្រហ្មទណ្ឌយុត្តិធម៌</td></tr>
</table>

| | | |
|---|---|---|
| CJ6 | តាមដានករណីជួញដូរមនុស្ស ដើម្បីធ្វើឱ្យប្រាកដថា មានការប្រុងប្រយ័ត្ន និងដំណើរត្រឹមត្រូវនៃការផ្តន្ទាទោស | កម្មជនរងគ្រោះ (ខ)ស្តង់ដារអន្តរជាតិនៃដំណើរការចាំបាច់ និងភាពត្រឹមត្រូវនៃការ អនុវត្ត នៅក្នុងការស៊ើបអង្កេត និងការផ្តន្ទាទោសករណីជួញដូរមនុស្ស (គ)ការទូទាត់សំណងដែលប្រើ ប្រាស់ជាការបំពេញបន្ថែមពីលើកិច្ចប្រឹងប្រែងខាងយុត្តិធម៌ព្រហ្មទណ្ឌដែលផ្តល់ជម្រើស បន្ថែមសម្រាប់ ជនរងគ្រោះ ដែលស្វែងរកការគាំទ្រខាងផ្លូវច្បាប់ (ឃ)ចៅក្រមយល់ដឹងអំពីតួនាទីរបស់ពួកគេ ក្នុងនាមជាអាជ្ញាកណ្តាលឯករាជ្យ និងគ្មានការលំអៀងនៅក្នុងករណីជួញដូរមនុស្សដោយសង្កត់ធ្ងន់លើ ការបង្ហាញអំពីភស្តុតាងដែលគួរជឿបាននៅក្នុងករណីនានា និងការដាក់ទម្ងន់ទោស ដោយគ្មានការ សង្ស័យសមហេតុផល ។ |
| CJ 7 | ពង្រឹងលទ្ធភាពរបស់ជនរងគ្រោះក្នុងការ ទទួលបានសេវាកម្មយុត្តិធម៌ និងការទូទាត់សំណងតាម រយៈការជួសជុលសំណងរដ្ឋប្បវេណី | |

| ផ្នែក 3: កិច្ចការពារ  ការស្តារនីតិសម្បទា  និងការធ្វើសមាហរណកម្ម | | |
|---|---|---|
| សកម្មភាព | | ចំណុចដៅ |
| ★PRO1 | គោលការណ៍ណែនាំសម្រាប់ការកំណត់អត្តសញ្ញាណជនរងគ្រោះ និងស្តង់ដារនីតិវិធីប្រតិបត្តិការ (SOPs) | ៣.១ ប្រព័ន្ធ និងគោលការណ៍ណែនាំ ត្រូវដាក់ឱ្យអនុវត្ត និងដំណើរការ ដើម្បីធានាថា ជនរងគ្រោះនៃការ ជួញដូរត្រូវបានកំណត់អត្តសញ្ញាណ និងទទួលជំនួយជាលក្ខណៈបុគ្គល សមស្របទៅតាមភេទ បន្ទាប់ ពីឧត្តមប្រយោជន៏របស់ ពួកគេត្រូវបានកំណត់ ។ ផ្តល់ព័តិមានតាមភាសាដែលពួកគេអាចយល់បាន ហើយការកែលម្អការកំណត់អត្ត សញ្ញាណជនរងគ្រោះត្រូវបានវាស់តាមរយៈការវាយតម្លៃនិង និងមតិ យោបល់របស់ជនរងគ្រោះនៃការជួញដូរ ។<br>៣.២ ប្រព័ន្ធ និងគោលការណ៍ណែនាំ ត្រូវបានដាក់ឱ្យអនុវត្ត និងមានដំណើរការ ដើម្បីធានាថា ជនរងគ្រោះនៃការជួញដូរមិនស្ថិតក្រោមការឃុំឃាំងពីសំណាក់អាជ្ញាធរពង្រឹងការអនុវត្តច្បាប់ ឬនៅតាមជម្រំ ឬកន្លែងឃុំគ្រងដទៃទៀត ដោយមិនស្របតាមឆន្ទៈរបស់ជនរងគ្រោះឡើយ ។<br>៣.៣ ប្រព័ន្ធ និងគោលការណ៍ណែនាំ ត្រូវបានដាក់ឱ្យអនុវត្តនិងដំណើរការ ដើម្បីធានាថា ជនរងគ្រោះនៃ ការជួញដូរបានទទួលជម្រើសដែលមានសុវត្ថិភាព និងទាន់ពេលវេលាសម្រាប់ការវិលត្រឡប់ និង មាតុភូមិនិវត្តន៏ ដោយមានការកែលម្អកិច្ចសហប្រតិបត្តិការឆ្លងដែន ត្រូវបានវាស់តាមរយៈការវាយ តម្លៃនិងនិងមតិយោបល់របស់ |
| PRO2 | ការតាមដាន និងរាយការណ៍ អំពីការឃុំទុកជនរងគ្រោះនៃការជួញដូរ | |
| ★PRO3 | គោលការណ៏ណែនាំ និងនីតិវិធីប្រតិបត្តិស្តង់ដារ (SOPs)សម្រាប់ការបញ្ជូនត្រឡប់/ការមាតុភូមិ និវត្តន៏ និងការពារជនរងគ្រោះ | |
| PRO4 | គាំទ្រដល់ការអនុវត្តគោលការណ៏ណែនាំ និងការកសាងសមត្ថភាពសម្រាប់អ្នកគ្រប់គ្រងមណ្ឌល ការថែទាំជំនួស និងយន្តការបញ្ជូន | |

| | | |
|---|---|---|
| ★PRO5 | ជំនួយសមាហរណកម្ម( ឡើងវិញ) ប្រកបដោយប្រសិទ្ធិភាព | ជនរងគ្រោះនៃការជួញដូរ។<br>៣.៤ ប្រព័ន្ធ និងគោលការណ៍ណែនាំ ត្រូវបានដាក់ឱ្យអនុវត្ត និងមានដំណើរការ ដើម្បីធានាថា ជនរងគ្រោះ នៃការជួញដូរបានទទួលជម្រើសសមាហរណកម្មសមស្របជាលក្ខណៈបុគ្គល ដែលរួមទាំង ជម្រើស សមស្រប និងមាននិរន្តរភាពនៃរបរចិញ្ចឹមជីវិត ដោយមានការកែលម្អសេវាកម្មជាបន្តបន្ទាប់ ដែល ត្រូវបានវាស់វែងតាមរយៈការវាយតម្លៃនិង និងមតិយោបល់របស់ជនរងគ្រោះនៃការជួញដូរ។<br>៣.៥ ក្រុមអ្នកផ្តល់សេវាកម្មជួយជនរងគ្រោះទទួលការបណ្តុះបណ្តាលត្រឹមត្រូវ បានបង្កើតជាបណ្តាញ និងធ្វើការងារតាមតួនាទីរៀងៗខ្លួន តាមស្តង់ដារអន្តរជាតិចំពោះគុណភាពនៃការថែទាំ និងក្រមសីលធម៌នៃការយកចិត្តទុកដាក់ ចំពោះជនរងគ្រោះនៃការជួញដូរ។ |
| PRO 6 | ពិនិត្យតាមដានប្រសិទ្ធិភាពនៃជំនួយជនរងគ្រោះ និងករណីនៃការរងគ្រោះម្តងទៀត ឬជនរងគ្រោះក្លាយជាឈ្មួញកណ្តាល /អ្នកជួញដូរ | |
| PRO 7 | ការបណ្តុះបណ្តាលឯកទេស និងការ គាំទ្របច្ចេកទេស សម្រាប់អភិក្រម ដែលផ្អែកលើសិទ្ធិ និងតាម បុគ្គល នៅក្នុងកិច្ចការពារនិងគាំទ្រជនរងគ្រោះ | |

| ផ្នែក 4: វិធានការទប់ស្កាត់ និងកាត់បន្ថយភាពងាយរងគ្រោះ | | |
|---|---|---|
| | **សកម្មភាព** | **ចំណុចដៅ** |
| ★PRE 1 | កិច្ចផ្តួចផ្តើមកាត់បន្ថយភាពងាយរងគ្រោះ | **៤.១** វិធានការថ្នាក់តំបន់ ជាតិ និង/ឬមូលដ្ឋាន ដើម្បីកំណត់អត្តសញ្ញាណ និងកាត់បន្ថយភាពងាយរង គ្រោះនៃការជួញដូរមនុស្ស ត្រូវបានបង្កើតឡើង សាកល្បង ចែករំលែក និងចម្លងទៅអនុវត្តនៅ កន្លែងផ្សេងទៀត ។<br>**៤.២** បណ្តាញការពារឃ្លាំមើល ត្រូវបានបង្កើតឡើង និងពង្រឹង ជាពិសេស នៅកន្លែងដែលមានការជួញ ដូរច្រើន នៅប្រទេសប្រភព និងប្រទេសជាគោលដៅ ដើម្បីកំណត់អត្តសញ្ញាណ និង ដោះស្រាយ តម្រូវ ការរបស់ប្រជាពលរដ្ឋដែលកំពុងប្រឈមគ្រោះថ្នាក់ ។<br>**៤.៣** យុទ្ធនាការលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងតស៊ូមតិ ដែលលើកឡើងអំពីការជួញដូរមនុស្ស ការធ្វើអន្តោប្រវេសន៍ដោយសុវត្ថិភាព និងសិទ្ធិពលកម្មត្រូវបានរៀបចំឡើង សាកល្បង និងពង្រីកទៅ អនុវត្តនៅកន្លែងផ្សេង ស្របតាមការវាយតម្លៃផលប៉ះពាល់ជាវិជ្ជមានរបស់គេ អំពីការផ្លាស់ប្តូរ ឥរិយាបទ ។<br>**៤.៤** ច្បាប់ការងាររបស់ជាតិ និងនយោបាយពាក់ពន្ធ័ដទៃទៀត ត្រូវបានដាក់ឱ្យអនុវត្ត ដើម្បីការពារសិទ្ធិ កម្មករទាំងអស់  ផ្អែកលើគោលការណ៍គ្មានការរើសអើង និងសមភាព ដោយមានយន្តការអធិការ កិច្ច និងដោះស្រាយពាក្យបណ្តឹង ដែលដំណើរការ ដើម្បីកំណត់អត្តសញ្ញាណ និងដាក់ទណ្ឌកម្មការ កេងប្រវ័ញ្ចលើពលករ ។<br>**៤.៥** កិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន ត្រូវបានពង្រឹង ដើម្បីពង្រីកតួនាទីសកម្មរបស់ពួកគេក្នុង ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ។ ប្រការនេះ អាចរាប់បញ្ចូល ប៉ុន្តែមិនមែនកំហិតត្រឹមជំនួញ និងសមាគមអ្នក ជំនួញនៅក្នុងវិស័យទេស ចរណ៍ ការដឹកជញ្ជូន ការកំសាន្ត និងឧស្សាហកម្មផ្តោត លើការនាំចេញ ឬវិស័យដទៃ ទៀត |
| PRE 2 | ប្រព័ន្ធការពារនិងឃ្លាំមើលសហគមន៍ និងព្រំដែន | |
| PRE 3 | ការលើកកម្ពស់ការយល់ដឹងជាសាធារណៈ | |
| ★PRE 4 | ពង្រឹងយន្តការប្រឆាំងនឹងការកេងប្រវ័ញ្ចពលកម្ម និងការជួញដូរតាមរយៈការរៀបអាពាហ៍ពិពាហ៍ | |
| PRE 5 | ពង្រឹងតួនាទី និងសមត្ថភាពរបស់មន្ត្រីមិនមែនប៉ូលីស ក្នុងការអនុវត្តច្បាប់ជាតិ ដើម្បីកាត់បន្ថយ ការកេងប្រវ័ញ្ច | |
| PRE 6 | កិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន និងការឱ្យក្រុមហ៊ុន មានការទទួលខុសត្រូវខាងសង្គម | |

| | | |
|---|---|---|
| | | ដែលមានអាណត្តិខាងផ្នែកសង្គម ក្នុងការចូលរួមប្រឆាំងការ ជួញដូរ ។ |

| ផែន 5: ប្រព័ន្ធពិនិត្យតាមដាន វាយតម្លៃ និងទិន្នន័យសម្រាប់ ការងារប្រឆាំងការជួញ ដូរមនុស្ស | | |
|---|---|---|
| | **សកម្មភាព** | **ចំណុចដៅ** |
| **M&E 1** | កសាងប្រព័ន្ធ និងពង្រឹងសមត្ថភាពក្នុងការ ប្រឆាំងនឹង ការជួញដូរមនុស្ស | **៥.១** ប្រព័ន្ធទិន្នន័យដែលប្រមូលទិន្នន័យសំខាន់ៗអំពីការជួញដូរមនុស្សត្រូវបានបង្កើតឡើង ដាក់ឱ្យដំណើរ ការ និងបានទទួលការគាំទ្រតាមរយៈអាណត្តិ និងថវិការបស់រដ្ឋាភិបាល ។<br>**៥.២** ការងារប្រឆាំងនឹងការជួញដូរមនុស្សត្រូវបានពង្រឹង តាមរយៈការលើកម្ពស់ការស្រាវជ្រាវ និងការ ងារវិភាគ ដែលរួមទាំងការរកឱ្យឃើញនូវកត្តាដែលនាំឱ្យមានភាពងាយរងគ្រោះ បែបបទនៃប្រតិ បត្តិការនៃអ្នកជួញដូរ និងប្រសិទ្ធិភាពនៃច្បាប់ គោលនយោបាយ និងវិធានការនានាប្រឆាំងការជួញ ដូរមនុស្ស ។ |
| **M&E 2** | ការរៀបចំចងក្រងស្ថិតិផ្លូវការ | |
| **M&E 3** | ស្រាវស្រាវស្ថិតិចំនួន ផ្លូវឆ្លងកាត់ ទម្រង់ និងនិន្នាការនៃការ ជួញដូរមនុស្ស | **៥.៣** របាយការណ៍ត្រួតពិនិត្យប្រចាំឆ្នាំ និងការវាយតម្លៃចុងក្រោយអំពីការរីកចម្រើននៃរដ្ឋាភិបាល COMMIT លើចំណុចដៅ និងគោលដៅនានាដែលបានឯកភាពគ្នា នៅក្នុង COMMIT SPA III (2011-2013) ត្រូវ បានបោះពុម្ពផ្សាយ ។ |
| **M&E 4** | ការពិនិត្យតាមដាន វាយតម្លៃ និងរាយការរបស់ COMMIT | **៥.៤** ការវាយតម្លៃផលប៉ះពាល់នៅក្រោម COMMIT SPA III ដែលវាស់ឥទ្ធិពលពីកិច្ចប្រឹងប្រែង ពហុទីភ្នាក់ងារ ចំពោះការទប់ស្កាត់ កិច្ចការពារ និងការផ្តន្ទាទោស នៅទូទាំងតំបន់មេគង្គ ត្រូវបាន អនុវត្តរួចរាល់ នៅក្នុង រយៈពេលមួយឆ្នាំនៃការបញ្ចប់ COMMIT SPA III ។ |

# ឧបសម្ព័ន្ធ ក

## អនុស្សរណៈនៃការយោគយល់នៅក្រោម COMMIT (2004)

# ឧបសម្ព័ន្ធ ២

# អនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំង អំពើជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ

យើងជាតំណាងរដ្ឋាភិបាលនៃបណ្តាប្រទេសនៅមហាអនុតំបន់មេគង្គដែលរួមមានៈ ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ៖

**ដោយមានកង្វល់យ៉ាងខ្លាំង** ចំពោះទុក្ខវេទនាដែលបណ្តាលមកពីអំពើជួញដូរមនុស្ស ដែលកើតមានឡើងនៅក្នុងមហាអនុតំបន់មេគង្គ និងពីបណ្តាប្រទេសនៃមហាអនុតំបន់មេគង្គទៅកាន់តំបន់ដទៃទៀត ក្នុងពិភពលោក ។

ដោយយល់ឃើញថា ប្រការដែលមនុស្សត្រូវបានគេនាំយកទៅធ្វើជាជំនួញជួញដូរ លក់ ទិញ ពង្រត់ រក្សាទុក និងបង្ខាំងក្នុងស្ថានភាពកេងប្រវ័ញ្ចដែលប្រឆាំងទៅនឹងសិទ្ធិជាមូលដ្ឋាន គឺជាអំពើដែលមិនអាចទទួលយក បានឡើយ ។

**ដោយទទួលស្គាល់ថា** ភាពក្រីក្រកង្វះលទ្ធភាពទទួលបានការអប់រំ និងវិសមភាព រួមទាំងការមិនទទួលបាននូវឱកាសស្មើគ្នាផង ជាកត្តាជំរុញឱ្យអ្នកទាំងនោះងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ។

**ដោយទទួលស្គាល់បន្ថែមទៀតថា** មានទំនាក់ទំនងរវាងអំពើជួញដូរមនុស្សទៅនឹងតំរូវការផ្នែកពលកម្ម និងសេវាកម្មផ្លូវភេទបែបកេងប្រវ័ញ្ច ដែលចេះតែរីករាលដាលឡើង ។

**ដោយទទួលស្គាល់ថា** អំពើជួញដូរ មានសភាពកាន់តែធ្ងន់ធ្ងរឡើង ដោយសារតែឥរិយាបថរើសអើងនានា ដោយអំពើរើសអើងក្នុងការប្រតិបត្តិនានា ក៏ដូចជាអំពើរើសអើងក្នុងគោលនយោបាយស្តីពីតួនាទីជេនឌ័រ អាយុ សញ្ជាតិ ជាតិសាសន៍ និងការបែងចែកក្រុមមនុស្សនានាក្នុងសង្គម ។

**ដោយសង្កត់ធ្ងន់ថា** កុមារ និងស្ត្រី ដែលបានក្លាយខ្លួនជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ជាពិសេស

គឺងាយទទួលរងគ្រោះថ្នាក់ ហើយត្រូវការវិធានការពិសេស ដើម្បីធានានូវកិច្ចការពារ និងសុខុមាលភាពរបស់ពួកគេ ។

**ដោយមានក្ដីបារម្ភ** ចំពោះការជាប់ពាក់ព័ន្ធរបស់ក្រុមសមាជិកសហគមន៍ និងក្រុមឧក្រិដ្ឋជនដែលមានការចាត់តាំង ក្នុងអំពើជួញដូរមនុស្ស ។

**ដោយទទួលស្គាល់ថា** ការពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌជាតំរូវការចាំបាច់ ក្នុងការឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស ពីព្រោះថាវាគឺជាការផ្ដល់សុវត្ថភាពយុត្តិធម៌ដល់ជនរងគ្រោះ ក៏ដូចជាការបញ្ចប់និទណ្ឌភាពរបស់ជនល្មើស ព្រមទាំងជនដ៏ទៃទៀតដែលទទួលអត្ថប្រយោជន៍ពីឧក្រិដ្ឋកម្មនេះ ។

**ដោយទទួលស្គាល់នូវ** សារៈសំខាន់នៃការផ្ដន្ទាទោសប្រកបដោយប្រសិទ្ធភាព និងធ្វើឱ្យមានភាពសមាមាត្រទៅនឹងអំពើដែលជនល្មើសបានប្រព្រឹត្ត រួមទាំងការចេញជាបទបញ្ញាតិ សំរាប់ការឃាត់ទុកនិង ការរឹបអូសយកទ្រព្យសម្បត្តិរបស់ពួកគេ ហើយនិងការចេញជាបទបញ្ញាតិ សំរាប់ការប្រើប្រាស់ទ្រព្យសម្បត្តិរបស់ជន ល្មើសឱ្យជាប្រយោជន៍ដល់ជនរងគ្រោះ ។

**ដោយទទួលស្គាល់ថា** ការចូលរួមដោយឈរលើមូលដ្ឋានស្ម័គ្រចិត្តរបស់ជនរងគ្រោះដែលបានរំដោះរួចពីអំពើជួញដូរនេះ មានសារៈសំខាន់អាចបង្កើត, អនុវត្ត និងវាយតំលៃ លើកិច្ចអន្តរាគមន៍ប្រឆាំងនឹងអំពើជួញដូរ មនុស្ស និងធានាឱ្យមានការចោទប្រកាន់លើជនល្មើសជួញដូរមនុស្ស ។

**ដោយទទួលស្គាល់** អំពីសារសំខាន់នៃតួនាទីរបស់ភ្នាក់ងារគាំទ្រជនរងគ្រោះខាងផ្នែកបង្ការទប់ស្កាត់,កិច្ចការ ពារការផ្ដន្ទាទោស ការជួយសង្គ្រោះ ការធ្វើមាតុភូមិនិវត្ត ការស្ដារនិតិសម្បទា និងការធ្វើសមាហរណកម្ម ប្រមទាំងការគាំទ្រដល់ការឆ្លើយតបឱ្យមានការពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទ័ណ្ឌ ។

**ដោយទទួលស្គាល់ថា** រដ្ឋាភិបាលនៃអនុស្សារណៈនេះ ប្រកាន់យកនូវវិធានការឱ្យបានជាអតិបរមា តាមដែលធនធានខ្លួនមាន ជាលក្ខណៈបុគ្គល(របស់ប្រទេស) និងតាមរយៈជំនួយ និង កិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីធ្វើឱ្យសំរេចឱ្យបានប្រសើរឡើងនូវការប្ដេជ្ញាចិត្ត ដែលទទួលស្គាល់ ដោយអនុស្សារណៈ តាមរយៈមធ្យោបាយសមស្របទាំងអស់ ។

**ដោយរំលឹកឡើងវិញនូវ** សេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស ជាពិសេសមាត្រាទី៤ ដែលបានចែង ថា" គ្មានជនណាម្នាក់ត្រូវស្ថិតក្នុងទាសភាព ឬស្ថិតក្នុងភាពជាអ្នកបម្រើជាចំថ្លៃឡើយ ។ ទាសភាព និង ទាសពាណិជ្ជកម្ម ត្រូវហាមឃាត់ ទោះតាមទម្រង់ណាក៏ដោយ ។"

**ដោយក្តីកោតសរសើរ** ដល់ប្រទេសក្នុងមហាអនុតំបន់មេគង្គទាំងឡាយណាដែលបានផ្តល់សច្ចាប័នលើ និង/ឬ សុំចូលជាសមាជិក នៃឧបករណ៍ច្បាប់អន្តរជាតិសំខាន់ៗ ដែលពាក់ព័ន្ធទៅនឹងអំពើជួញដូរមនុស្ស និងទាក់ទងទៅនឹងការកេងប្រវ័ញ្ចមនុស្ស ដែលរួមបញ្ចូលមាន :

- អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន និងពិធីសាររបស់អនុសញ្ញានេះ ស្តីពីការទប់ស្កាត់ ការបង្ក្រាប និងការផ្តន្ទាទោសអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ។
- អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងស្ត្រីភេទ ។
- អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ និងពិធីសាររបស់អនុសញ្ញានេះ ស្តីពីការលក់ដូរកុមារ ពេស្យាកម្មកុមារ អំពើអាសអាភាសលើកុមារ និង ពិធីសារស្តីពីការពាក់ព័ន្ធរបស់កុមារ ទៅក្នុងជំលោះប្រដាប់អាវុធ ។
- អនុសញ្ញាអង្គការពលកម្មអន្តរជាតិស្តីពីពលកម្មដោយបង្ខំ ( លេខ២៩ និង ១០៥ )
- អនុសញ្ញាអង្គការពលកម្មអន្តរជាតិ (លេខ១៨២) ស្តីពីការហាមឃាត់ និងការចាត់វិធានបន្ទាន់ ដើម្បីលុបបំបាត់រាល់ទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ។

ហើយនិងលើកទឹកចិត្តដល់បណ្តាប្រទេសទាំងឡាយណាដែលពុំទាន់បានផ្តល់សច្ចាប័ននិង/ឬចូលជាសមាជិកលើលិខិតឧបករណ៍អន្តរជាតិទាំងអស់នេះ សូមឱ្យធ្វើការចូលជាសមាជិកលើឧបករណ៍អន្តរជាតិទាំងនេះ ឱ្យបានយ៉ាងឆាប់បំផុត តាមដែលអាចធ្វើទៅបាន។

**ដោយអះអាងឡើងវិញថា** សារៈសំខាន់នៃគោលការណ៍ជាអនុសាសន៍ និងការណែនាំរបស់អង្គការសហប្រជាជាតិ ស្តីអំពីសិទ្ធិមនុស្ស និងអំពើជួញដូរមនុស្សដែលមាននៅក្នុងរបាយការណ៍របស់ ឧត្តមស្នងការអង្គការសហប្រជាជាតិ នៅឆ្នាំ ២០០០ ដែលបញ្ជូនទៅក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមរបស់អង្គការសហប្រជា ជាតិ ។

**ដោយអះអាងឡើងវិញថា** ដោយមានការផ្តួចផ្តើមគំនិត និងការប្តេជ្ញាចិត្តថ្នាក់តំបន់លើការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ។

**ដោយស្វាគមន៍** ចំពោះអនុស្សរណៈនៃការយោគយល់គ្នាឈានមុខគេ រវាងកម្ពុជា-ថៃ ស្តីពីកិច្ចសហការទ្វេភាគីដើម្បីលុបបំបាត់អំពើជួញដូរស្ត្រី និងកុមារ និងការជួយដល់ជនរងគ្រោះពីអំពើជួញដូរមនុស្ស (២០០៣) និងរាល់កិច្ចខិតខំប្រឹងប្រែងរៀបចំកិច្ចព្រមព្រៀងទ្វេភាគីប្រហាក់ប្រហែលគ្នា ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស នៅមហាអនុតំបន់មេគង្គ ។

**ដោយស្វាគមន៍** ចំពោះសារសំខាន់នៃបណ្តាកិច្ចព្រមព្រៀងទ្វេភាគី ដូចជា អនុស្សរណៈយោគយល់គ្នាលើកិច្ចសហប្រតិបត្តិការនៃការប្រើប្រាស់ពលកម្មរវាងថៃនិងកម្ពុជា រវាងថៃនិងសាធារណរដ្ឋប្រជាមានិត ឡាវ និងរវាងថៃនិងសហភាពមីយ៉ានម៉ា ក្នុងការលើកស្ទួយសុវត្ថភាព សណ្តាប់ធ្នាប់ ការគ្រប់គ្រងល្អលើទេសន្តរប្រវេសន៍ ដោយហេតុថា វិធានការនេះ គឺបំរើដល់ការកាត់បន្ថយ តំរូវការសេវាកម្មទេសន្តរប្រវេសន៍ ខុសច្បាប់ដែលផ្តល់ឱកាសឱ្យ ក្រុមជួញដូរមនុស្ស ។

**ដោយមានគោលបំណង** ពេញលេញថា អនុស្សរណៈនេះ បង្ហាញពីឆន្ទះនយោបាយបន្តរបស់រដ្ឋភិបាលប្រទេសទាំងបួនដើម្បីសហការប្រឆាំងអំពើជួញដូរមនុស្ស ។ ហើយនិង

**ដោយអំពាវនាវ** ដល់បណ្តាប្រទេសនៅក្រៅមហាអនុតំបន់មេគង្គ ឱ្យចូលរួមជាមួយនឹងបណ្តាប្រទេសយើង ដើម្បីធ្វើការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ។

**អាស្រ័យហេតុនេះ យើងសូមប្តេជ្ញាចិត្តជាឱឡារឹក** អនុវត្តលើសកម្មភាពដូចខាងក្រោម :

## I -វិស័យគោលនយោបាយ និងកិច្ចសហប្រតិបត្តិការ (ថ្នាក់ជាតិនិងអន្តរជាតិ) :

**១-លើកទឹកចិត្តដល់** ការប្រើប្រាស់និយមន័យនៃអំពើជួញដូរមនុស្សដែលមានចែងនៅក្នុង ពិធីសារស្តីពីការបង្ការ ការបង្រ្កាប និងការផ្តន្ទាទោសជនល្មើស ជាពិសេសស្ត្រី និងកុមារ ដែលពិធីសារនេះ គឺជាការបំពេញបន្ថែម លើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីឧក្រិដ្ឋកម្មឆ្លងដែន ដែលមានអង្គការចាត់តាំង ។

**២-រៀបចំ** ផែនការសកម្មភាពជាតិប្រឆាំងនឹងអំពើជួញដូរមនុស្សគ្រប់រូបភាព ។

**៣-ធ្វើការឆ្ពោះទៅ** បង្កើត និងពង្រឹង គណៈកម្មាធិការជាតិពហុវិស័យស្តីពីអំពើជួញដូរមនុស្ស ដែលមានតួនាទីសំរបសំរួលដល់ការអនុវត្តផែនការសកម្មភាពជាតិ និងរាល់បណ្តាកិច្ចអន្តរាគមន៍ប្រយុទ្ធប្រឆាំង នឹងអំពើជួញដូរមនុស្ស ។

**៤- បង្កើតយន្តការ** ដើម្បីពង្រឹងកិច្ចសហការថ្នាក់តំបន់ និងការផ្លាស់ប្តូរពតិមាន ព្រមទាំងតែងតាំងក្រុមការងារបង្គោលថ្នាក់ជាតិ ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ។

**៥-ធ្វើឱ្យកាន់តែប្រសើរឡើងដល់** កិច្ចសហប្រតិបត្តិការថ្នាក់តំបន់ ប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សជាពិសេសតាមរយៈ កិច្ចព្រមព្រៀង ទ្វេភាគី និងពហុភាគី ហើយនិង

**៦-ពង្រឹង** កិច្ចសហប្រតិបត្តិការជាមួយនឹង រដ្ឋាភិបាលនានា អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលដើម្បីការប្រយុទ្ធ នឹងអំពើជួញដូរមនុស្ស ។

## II - វិស័យក្របខ័ណ្ឌច្បាប់ ការអនុវត្តច្បាប់ និងយុត្តិធម៌ :

**៧-អនុម័ត និងអនុវត្ត** ច្បាប់សមស្របប្រឆាំងនឹងអំពើជួញដូរមនុស្ស ឱ្យបានឆាប់តាមដែលអាចធ្វើ ទៅបាន ។

**៨-អនុម័ត** គោលការណែនាំសមស្រប និងផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីពាក់ព័ន្ធ ដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សឱ្យបានរហ័ស និងត្រឹមត្រូវ និងដើម្បីធ្វើឱ្យប្រសើរឡើង ដល់ការស៊ើបអង្កេត ការចោទប្រកាន់ និងដំណើរការរបស់តុលាការ ។

**៩-ស៊ើបអង្កេត** ចាប់ខ្លួន ចោទប្រកាន់ និងផ្តន្ទាទោស ជនល្មើសដែលប្រព្រឹត្តអំពើជួញដូរមនុស្ស ឱ្យស្របទៅតាមច្បាប់ជាតិ ។

**១០-បង្កើតឱ្យមាន** ជំនួយខាងផ្នែកច្បាប់ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការផ្តល់ពតិមាន ជាភាសា ដែលជនរងគ្រោះអាចយល់បាន ។

**១១-បង្កើតឱ្យមាន** កិច្ចសហប្រតិបត្តិការជាក់លាក់ និងមានប្រសិទ្ធភាព ក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទ័ណ្ឌ ដើម្បីលុបបំបាត់និទណ្ឌភាពរបស់ជនល្មើស និងផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ ។

**១២-ពង្រឹង** កិច្ចសហប្រតិបត្តិការឆ្លងដែនក្នុងការអនុវត្តច្បាប់ជាមួយនឹង បណ្តាប្រទេសទាំង៦ នៃមហាអនុតំបន់មេគង្គ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈដំណើរការរបស់ ប្រព័ន្ធយុត្តិធម៌ ព្រហ្មទ័ណ្ឌ។

**១៣-ផ្តល់នូវ** ការគាំទ្រផ្នែកបុគ្គលិក និងថវិកាចាំបាច់ ដល់សមត្ថភាពឆ្លើយតបលើបញ្ហាជួញដូរមនុស្សនៅក្នុងចំណោមអាជ្ញាធរជាតិអនុវត្តច្បាប់ ។

**១៤-ជំរុញឱ្យមាន** កិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគី ក្នុងចំណោម ប្រទេសទាំង៦ នៃមហាអនុតំបន់មេគង្គ ដើម្បីជួយគ្នាទៅវិញទៅមក នៅក្នុងដំណើរយុត្តិធម៌ព្រហ្មទណ្ឌ ។

## III. វិស័យការពារ ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្ម :

**១៥-លើកកំពស់** ដល់ការយល់ដឹងជ្រាលជ្រៅលើបញ្ហាជនរងគ្រោះ និងកុមារ លើគ្រប់វិស័យពាក់ព័ន្ធទៅនឹងជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។

**១៦-ធានាថា** ជនដែលត្រូវបានកំណត់អត្តសញ្ញាណថាជាជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស នឹងមិនត្រូវឃុំខ្លួនដោយអាជ្ញាធរអនុវត្តច្បាប់ឡើយ ។

**១៧-ផ្តល់ដល់** ជនរងគ្រោះដោយអំពើជួញដូរមនុស្សគ្រប់រូប នូវជំរក ជំនួយខាងផ្លូវកាយ ចិត្តសាស្ត្រ សង្គម ផ្លូវច្បាប់ ការអប់រំ និងជំនួយខាងផ្នែកថែរក្សាសុខភាព ។

**១៨-អនុម័ត** គោលនយោបាយ និងយន្តការ ដើម្បីការពារ និងទ្រទ្រង់ ដល់អ្នកដែលត្រូវបានគេជួញដូរ។

**១៩-ពង្រឹង** សមត្ថភាពមន្ត្រីស្ថានទូត និងស្ថានកុងស៊ុលនានា ដើម្បីធានាថាពួកគេអាចជួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាពឡើង ។

**២០-ធានាឱ្យមាន** កិច្ចសហប្រតិបត្តិការឆ្លងដែនប្រកបដោយសុវត្ថភាព លើការបញ្ជូនត្រឡប់វិញ របស់ ជនរងគ្រោះដោយអំពើជួញដូរមនុស្ស, ដោយរួមបញ្ចូលកិច្ចទ្រទ្រង់នានា ដើម្បីធានាសុខមាលភាពរបស់ពួកគេ ។ ហើយនិង

**២១-ធ្វើការរួមគ្នា** ដើម្បីសំរបសំរួលការស្តារនីតិសម្បទា និង ការធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្សប្រកបដោយជោគជ័យ និងការទប់ស្កាត់ពួកគេកុំឱ្យធ្លាក់ខ្លួនទៅក្នុងការជួញដូរជាថ្មីទៀត ។

## IV- ផ្នែកវិធានការបង្ការទប់ស្កាត់ :

**២២-អនុម័ត** វិធានការកាត់បន្ថយភាពងាយរងគ្រោះ រួមមាន: ការគាំទ្រកម្មវិធីកាត់បន្ថយភាពក្រីក្រ, ការបង្កើនឱកាសផ្នែកសេដ្ឋកិច្ច, ការធានាលទ្ធភាពទទួលបានគុណភាពខាងការអប់រំ, និង ការបណ្តុះបណ្តាល

មុខជំនាញ និងការផ្តល់ឯកសារចាំបាច់ខាងផ្លូវច្បាប់សំរាប់ការបញ្ជាក់អត្តសញ្ញាណ រួមមានលិខិតកំណើតជាដើម ។

**២៣-គាំទ្រ** ការបង្កើតបណ្តាញសហគមន៍ការពារទប់ស្កាត់ និងឃ្លាំមើល ដើម្បីធ្វើការកំណត់អត្តសញ្ញាណ និងផ្តល់អន្តរាគមន៍មុនដំបូងដល់ជនដែលប្រឈមមុខនឹងគ្រោះថ្នាក់ ។

**២៤-លើកកំពស់** ការយល់ដឹងជាសាធារណៈនៅគ្រប់លំដាប់ថ្នាក់ទាំងអស់ ទាំងភាពគ្រោះថ្នាក់ និង ផលប៉ះពាល់ជាអវិជ្ជមាននៃអំពើជួញដូរមនុស្ស និងជំនួយដែលមានដល់ជនរងគ្រោះ ។ ការលើកកំពស់ការយល់ដឹង គឺធ្វើឡើងរួមមាន តាមរយៈយុទ្ធនាការ ផ្សព្វផ្សាយពត៌មានជាសាធារណៈ និងការតស៊ូមតិ ។

**២៥-អនុវត្ត** ច្បាប់ការងារជាតិ ដើម្បីការពារសិទ្ធរបស់កម្មករទាំងអស់ ដោយផ្អែកទៅលើ គោលការណ៍នៃភាពគ្មានការរើសអើង និង សមភាព ។

**២៦-លើកទឹកចិត្ត** ដល់បណ្តាប្រទេសទទួលនូវអំពើជួញដូរមនុស្ស រួមទាំងប្រទេសនៅក្រៅ មហាអនុតំបន់មេគង្គ, ដើម្បីអនុវត្តឱ្យបានលើច្បាប់ជាតិដែលពាក់ព័ន្ធ ដើម្បីកាត់បន្ថយ ការកេងប្រវ័ញ្ច លើមនុស្សដែលបង្កើនកំលាំងឱ្យមានការបន្តនូវតំរូវការងារជួញដូរមនុស្ស, ហើយនិង ដើម្បីបង្ក្រាបបទឧក្រិដ្ឋជួញ ដូរស្ត្រីនិងកុមារ តាមរយៈកិច្ចសហប្រតិបត្តិការរវាងគ្នាទៅវិញទៅមក ។ ហើយនិង

**២៧- បង្កើន** កិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន ជាពិសេសឧស្សាហកម្មទេសចរណ៍ និង កំសាន្តនានា ដើម្បីធ្វើឱ្យវិស័យទាំងនេះ ប្រកាន់យកតួនាទីសកម្ម ក្នុងការប្រយុទ្ធប្រឆាំងនឹង អំពើជួញដូរមនុស្ស ។

## V- ផែនការសំរាប់ ការអនុវត្តន៍ តាមដាន និង វាយតំលៃ លើអនុស្សរណៈនៃការយោគយល់គ្នានេះ :

**២៨-បង្កើត** ផែនការសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរអនុតំបន់ដំបូងមួយ សំរាប់ឆ្នាំ ២០០៥-២០០៧ និងប្រមូលផ្តុំនូវកិច្ចខិតខំប្រឹងប្រែងចាំបាច់នានា ដើម្បីអនុវត្តឱ្យបានពេញលេញ លើផែន ការនេះ ។

**២៩- បង្កើត** នីតិវិធីនានា សំរាប់ការប្រមូលនិង វិភាគទិន្នន័យ និងពត៌មាន អំពីករណីជួញដូរមនុស្សនានា និងធានាថា យុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស គឺពឹងផ្អែកទៅលើការសិក្សាស្រាវជ្រាវ បទពិសោធន៍ និងការវិភាគ ដែលមានលក្ខណៈត្រឹមត្រូវ និងថ្មីៗ ។

**៣០-បង្កើតឱ្យមាន** ប្រព័ន្ធពិនិត្យតាមដានលើការអនុវត្តន៍ផែនការសកម្មភាព ដើម្បីវាយតំលៃលើស្ថានភាពនៅពេលបច្ចុប្បន្ន និងការរីកចំរើននៃប្រទេសនិមួយៗនៅក្នុងការអនុវត្តលើការប្តេជ្ញាចិត្ត ដែលមាននៅក្នុងអនុស្សរណៈនេះ ដោយរួមមាន ជាអប្បបរិមា ការពិនិត្យតាមដាន នៅឯកិច្ចប្រជុំមន្រ្តី ជាន់ខ្ពស់ (SOM) ប្រចាំឆ្នាំ ។

**៣១-ពិនិត្យឡើងវិញ** លើការអនុវត្តផែនការសកម្មភាព និងអនុម័តផែនការសកម្មភាពអនុតំបន់ថ្មី តាមរយៈកិច្ចប្រជុំថ្នាក់ក្រសួងនៃបណ្តាប្រទេសនៅមហាអនុតំបន់មេគង្គ នៅចុងឆ្នាំ ២០០៧ ។

**៣២-បង្កើត** ក្រុមការងារជាតិដើម្បីសហប្រតិបត្តិការជាមួយនឹងលេខាធិការដ្ឋាន COMMIT (កម្មវិធីអន្តរភ្នាក់ងាររបស់អង្គការសហប្រជាជាតិប្រឆាំង នឹងអំពើជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ UNIAP) និងជាមួយបណ្តាដៃគូដទៃទៀត ។

**៣៣-អញ្ជើញ** ភ្នាក់ងារមូលនិធិរបស់រដ្ឋាភិបាល ព្រមទាំង ភ្នាក់ងារពាក់ព័ន្ធនានារបស់អង្គការសហប្រជា ជាតិ និង បណ្តាអង្គការអន្តររដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងផ្នែកឯកជន ដើម្បីផ្តល់ជំនួយ ហិរញ្ញវត្ថុ សំភារៈនិងបច្ចេកទេស ដើម្បីទ្រទ្រង់កិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាល នៃបណ្តាប្រទេសនៅមហាអនុតំបន់មេគង្គ ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សរបស់ពួកគេ ដោយរួមមានការអនុវត្តន៍ អនុស្សរណៈនេះនិងផែនការសកម្មភាពខាងមុខ ។ ហើយនិង

**៣៤-ទទួលស្គាល់ថា** ការធ្វើវិសោធនកម្មនានាលើអនុស្សារណៈនេះ គឺអាចធ្វើទៅបាន នៅពេលអនាគត, រដ្ឋាភិបាលនានាកំណត់ពីដំណើរការខាងក្រោមក្នុងការធ្វើវិសោធនកម្មលើអនុស្សរណៈនេះ : (១) ប្រសិនបើមានរដ្ឋាភិបាលនៃប្រទេសបួន ក្នុងចំណោមប្រទេសទាំងប្រាំមួយ ដែលបានចុះហត្ថលេខា ខាង ក្រោម ជឿជាក់ថា អនុស្សរណៈនេះ គួរតែត្រូវកែប្រែ ហើយផ្តល់ពតិមានទៅលេខាធិកាដ្ឋាន ជាលាយ លក្ខអក្សរ ពេលនោះ នីតិវិធីនៃការពិគ្រោះយោបល់នឹងត្រូវធ្វើឡើងដោយលេខាធិការដ្ឋាន ដោយរបៀប សមស្រប ទៅវិញទៅមក ។ (២) គោលបំណងនៃនីតិវិធីនេះ ត្រូវឱ្យមានសំណើរលើ ការកែប្រែលើ អនុស្សរណៈ ។ (៣) ការកែប្រែណាមួយលើអនុស្សរណៈនេះ ត្រូវមានការយល់ព្រមជា ឯកច្ឆ័ន្ទ ដោយរដ្ឋាភិបាលរបស់ប្រទេសទាំងប្រាំមួយ ហើយការយល់ព្រមរបស់រដ្ឋាភិបាលរបស់ប្រទេសនិមួយៗ ត្រូវបញ្ជូនទៅលេខាធិការដ្ឋានជាលាយលក្ខអក្សរ ។

# ឧបសម្ព័ន្ធ ២

## សេចក្តីថ្លែងការណ៍រួមនៃ COMMIT (2007)

**សេចក្តីថ្លែងការណ៍រួម នៃក្រុមការងារសម្របសម្រួលគំនិតផ្តួចផ្តើមថ្នាក់រដ្ឋមន្ត្រី ប្រឆាំងការជួញដូរមនុស្ស នៅអនុតំបន់មេគង្គ**

**(សេចក្តីថ្លែងការណ៍_ខមមីត)**

១. **យើង**រដ្ឋមន្ត្រី និងតំណាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៏ និងសាធារណរដ្ឋសង្គមនិយមវៀតណាម និងជាសមាជិកស្ថាបនិកនៃគំនិតផ្តួចផ្តើមថ្នាក់រដ្ឋមន្ត្រីប្រឆាំងការជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ ហៅកាត់ថាដំណើរការ**ខមមីត** (COMMIT Process) បានជួបប្រជុំគ្នានៅទីក្រុង ប៉េកាំង នាឱកាសលើកទីបី នៃការចុះហត្ថលេខាលើអនុស្សរណៈខមមីត រួមគ្នា ដើម្បី :

២. **ការបញ្ជាក់អះអាង**នូវការប្តេជ្ញារបស់យើងចំពោះអនុស្សរណៈ**ខមមីត** ដែលបានចុះហត្ថលេខា នៅទីក្រុងយ៉ាំងហ្គូន ប្រទេសមីយ៉ាន់ម៉ា កាលពីថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៤ និងផែនការសកម្មភាពអនុតំបន់ **ខមមីត** ដែលត្រូវបានអនុម័តជាគោលការណ៍ នៅក្រុងហាណូយ កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៥ និងសេចក្តីសម្រេចផ្សេងៗទៀតគឺជាការបង្ហាញនូវឆន្ទៈនយោបាយម៉ឺងម៉ាត់របស់យើង ក្នុងកិច្ចសហប្រតិបត្តិការរវាងបណ្តាប្រទេស នៅក្នុងមហាអនុតំបន់មេគង្គ (GMS)ក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ពិសេសការជួញដូរកុមារ និងស្ត្រី

៣. **ការបញ្ជាក់អះអាង**នូវសេចក្តីប្រកាសជាឱឡារិករបស់យើង ក្នុងការឈានទៅសម្រេចគោលបំណងនៃការលុបបំបាត់សភាពមនុស្ស ដែលត្រូវបានគេជួញដូរ ទិញ លក់ ចាប់ជម្រិត ឃាំងទុក និងឃាត់ខ្លួនក្នុងស្ថានភាពកេងប្រវ័ញ្ច ដោយដកហូតសិទ្ធិជាមូលដ្ឋាននិងសិទ្ធិមនុស្សដែលមិនអាចលក់ដូរបាន

៤. **ការបញ្ជាក់អះអាង**អំពីសារៈសំខាន់នៃការយកចិត្តទុកដាក់ដល់អ្នកដែលត្រូវបានគេជួញដូរ ធ្វើជាបញ្ហាស្នូលនៃអន្តរាគមន៍ប្រឆាំងការជួញដូរមនុស្ស រាប់ទាំងការទទួលស្គាល់នូវសក្តានុពលរបស់ពួកគេ ក្នុងការរួមចំណែកដល់កិច្ចអភិវឌ្ឍន៍ ការអនុវត្តន៍ និងការវាយតម្លៃអន្តរាគមន៍ប្រឆាំងការជួញដូរមនុស្ស និងការគោរពសិទ្ធិរបស់អ្នកដែលត្រូវបានគេជួញដូរ នៅគ្រប់អន្តរាគមន៍ប្រឆាំងការជួញដូរមនុស្ស ដោយឈរលើមូលដ្ឋាននៃការស្ម័គ្រចិត្តទាំងស្រុង

៥. **ការទទួលស្គាល់បន្ថែម**នូវភាពស្មុគស្មាញនៃការជួញដូរមនុស្សថាជាបាតុភាព**ឧ**ក្រិដ្ឋ និងតម្រូវឱ្យមានការឆ្លើយតបខ្លាំងក្លាផ្នែកយុត្តិធម៌ព្រហ្មទណ្ឌនៅថ្នាក់ជាតិ និងថ្នាក់តំបន់ ដើម្បីស្វែងរកការបញ្ចប់និទណ្ឌភាពកំរិតខ្ពស់ ដែលអ្នកជួញដូរមនុស្សមួយចំនួនទទួលបានពេលបច្ចុប្បន្ន និងដើម្បីធានាយុត្តិធម៌ចំពោះជនរងគ្រោះ

៦. **ការអះអាង**អំពីសារៈសំខាន់នៃការឆ្លើយតបអន្តរវិស័យចំពោះការជួញដូរមនុស្ស និងការលើកសរសើរ ចំពោះកិច្ចប្រឹងប្រែងរបស់មន្ត្រីជាន់ខ្ពស់នៃក្រុមការងារ**ខមមីត**ថ្នាក់ជាតិ ដែលបានជំរុញឱ្យកិច្ចការនៃដំណើរការ**ខមមីត**បន្តឆ្ពោះទៅមុខ

៧. **ការទទួលស្គាល់**ថា ទោះបីជាស្ថានភាពនៃការឆ្លើយតបការជួញដូរមនុស្ស នៅមហាអនុតំបន់មេគង្គបានរីកចម្រើនចាប់តាំងពីការចុះហត្ថលេខាលើអនុស្សរណៈ**ខមមីត** និងការអនុវត្តន៍ផែនការសកម្មភាព អនុតំបន់ (២០០៥-២០០៧) ក៏ដោយ ឧបសគ្គចំពោះការលុបបំបាត់ការជួញដូរមនុស្សនៅតែកើតមាន

៨. **ការឧទ្ទិស**កម្លាំងកាយចិត្តរបស់យើងក្នុងការដោះស្រាយ**ឧ**បស័គ្គនិងបញ្ហាប្រឈមមុខ ដែលរារាំងដល់ការឆ្លើយតបមានប្រសិទ្ធភាពចំពោះការជួញដូរមនុស្ស ការរំលោភបំពាន និងអំពើកេងប្រវ័ញ្ចពាក់ព័ន្ធ ដោយរួមបញ្ចូលទាំងការលើកកំពស់ ការផ្តល់សិទ្ធិអំណាចដល់ពលរដ្ឋងាយរងគ្រោះ ក៏ដូចជាការព្រមព្រៀងគ្នាថាកិច្ចការទាំងនេះតម្រូវឱ្យបន្តការធ្វើសកម្មភាពបន្ទាន់ ក្នុងស្មារតីសាមគ្គីភាព និងសហប្រតិបត្តិការ រវាង និងក្នុងចំណោមបណ្តាប្រទេសនានា នៅក្នុងតំបន់ និង

៩.**ការទទួលស្គាល់**ការរួមចំណែករបស់គំនិតផ្តួចផ្តើម និងលិខិតុបករណ៍អន្តរជាតិ និងតំបន់ក៏ដូចជាការប្តេជ្ញាចិត្តនានា ចំពោះការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស

១០. **ហេតុនេះ នៅពេលនេះ យើងរួមគ្នាប្រកាសឡើង** នូវការប្តេជ្ញាចិត្តយ៉ាងមុឹងម៉ាត់របស់យើង ក្នុងការបន្តលើកកំពស់ស្មារតី**ខមមីត** រួមគ្នានិងប្រកបដោយសាមគ្គីភាព និងបន្តលើកំពស់ប្រតិបត្តិការនៃយន្តការកិច្ចសហប្រតិបត្តិការតំបន់ដ៏មានសារៈសំខាន់នេះ ដើម្បីឈានទៅបញ្ចប់ដោយជោគជ័យ នូវការរំលោភបំពាន និង

ការកេងប្រវ័ញ្ចពលរដ្ឋងាយរងគ្រោះ និងពលរដ្ឋដែលគេមិនបានយកចិត្តទុកដាក់ តាមរយៈការអះអាងដូចខាងក្រោមៈ

១១. ការប្តេជ្ញាចិត្តម៉ឺងម៉ាត់របស់យើងចំពោះការប្រយុទ្ធប្រឆាំងនឹងទាសភាពតាមគ្រប់រូបភាព រួមទាំងអំពីការកេងប្រវ័ញ្ចផ្លូវភេទចំពោះកុមារ និងមនុស្សពេញវ័យ ពលកម្មដោយបង្ខំ ពលកម្មកុមារ និងអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលមានចែងនៅក្នុងសេចក្តីថ្លែងការណ៍សាកលអំពីសិទ្ធិមនុស្ស និងលិខិតតុបករណ៍អន្តរជាតិដទៃទៀត និងទទួលស្គាល់ពីសារៈសំខាន់នៃលិខិតុបករណ៍អន្តរជាតិទាក់ទងនឹងការជួញដូរមនុស្ស ដែលមានរាយនាម នៅក្នុងអនុស្សារណៈ**ខមមីត**

១២. ការអះអាងរបស់យើងពីសារៈសំខាន់នៃគោលការណ៍ដែលចេញពីអនុសាសន៍របស់អង្គការសហប្រជាជាតិ និងគោលការណ៍ណែនាំស្តីពីសិទ្ធិមនុស្ស និងការជួញដូរមនុស្ស

១៣. ការប្តេជ្ញារបស់យើងក្នុងការពង្រឹងបន្ថែមទៀត នូវវឌ្ឍនភាពយ៉ាងច្រើនដែលសម្រេចបាន នៅក្នុងការអនុវត្តន៍អនុស្សរណៈ**ខមមីត** តាមរយៈផែនការសកម្មភាពអនុតំបន់ទី ១ (២០០៥-២០០៧) និងផែនការសកម្មភាពអនុតំបន់ទី ២ (២០០៨-២០១១)

១៤. ការប្តេជ្ញារបស់យើងចំពោះការទប់ស្កាត់ការជួញដូរមនុស្ស និងការធ្វើឱ្យប៉ះពាល់តាមរយៈសកម្មភាព ដែលសំដៅកំណត់អត្តសញ្ញាណ និងការការពារអ្នកដែលត្រូវបានគេជួញដូរ នៅគ្រប់ដំណាក់កាលទូទាំងវដ្តនៃការជួញដូរ ព្រមទាំងធ្វើយ៉ាងណាឱ្យសកម្មភាពផ្លូវការទាំងឡាយត្រូវបានប្រព្រឹត្តិទៅដោយមានការគោរព និងការពារទៅដល់សុវត្ថិភាព សេចក្តីថ្លៃថ្នូរ និងសិទ្ធិរបស់អ្នករងគ្រោះ

១៥. បំណងប្រាថ្នាដ៏មោះមុតរបស់យើងក្នុងការបន្តកិច្ចពិគ្រោះយោបល់និងសហការទ្វេភាគី និងពហុ ភាគី ព្រមទាំង កិច្ចសហការ រវាង និងក្នុងចំណោមបណ្តាប្រទេសនានា នៅក្នុងអនុតំបន់ (តាមវិស័យជាក់លាក់ និងទូទៅ) ក៏ដូចជាមួយស្ថាប័នថ្នាក់តំបន់ ដូចជាអាស៊ានជាដើម

១៦.	ការសម្រេចចិត្តយ៉ាងម៉ឺងម៉ាត់របស់យើងក្នុងការបន្តពង្រឹងសមត្ថភាពរបស់ក្រុមការងារ**ខមមីត** ថ្នាក់ជាតិ និងស្ថានប័នពាក់ព័ន្ធ ដើម្បីអនុវត្តនីសកម្មភាពដែលបានប្រគល់ជូន ក្រោមក្របខ័ណ្ឌខមមីត និងធ្វើយ៉ាងណាឱ្យក្រុម និងការងាររបស់ក្រុមនេះ បន្តទទួលបាននូវការគាំទ្រពេញទំហឹងពីរដ្ឋាភិបាលថ្នាក់ខ្ពស់បំផុត

១៧. ការសន្យារបស់យើងក្នុងការអនុវត្តនីវិធីសាស្ត្រសហការពិតប្រាកដ ដោយព្យាយាមស្វែងរក និងធ្វើឱ្យមានការចូលរួមយ៉ាងសកម្មប្រកបដោយចេរភាព ពីក្រុមសង្គមស៊ីវិល ទីភ្នាក់ងារគាំទ្រជនរងគ្រោះ អង្គការអន្តរជាតិ និងអ្នកត្រូវបានគេជួញដូរ ក្នុងការអនុវត្តនីកម្មវិធីប្រឆាំងការជួញដូរមនុស្ស រាប់ទាំងក្នុងការរៀបចំគម្រោង ការអភិវឌ្ឍន៍ ការតាមដាន និងការវាយតម្លៃកម្មវិធីទាំងនោះផងដែរ

១៨.	ជំនឿច្បាស់លាស់របស់យើងលើតម្លៃអនុវត្តជាក់ស្តែង និងតម្លៃជានិមិត្តរូបនៃវិធីសាស្ត្រមួយក្នុងការដាក់បុគ្គល និងសិទ្ធិរបស់គេទៅឱ្យដល់កំរិតកំពូលនៃច្បាប់ គោលនយោបាយ ឬអន្តរាគមន៍លើការជួញដូរមនុស្ស។

១៩. ការប្តេជ្ញាចិត្តរបស់យើង គឺគោលនយោបាយគ្មានការអនុគ្រោះណាមួយ ចំពោះការសមគំនិត ឬការចូលរួមរបស់វិស័យសាធារណៈទៅក្នុងឧក្រិដ្ឋកម្មជួញដូរមនុស្សឡើយ

២០. តទៅនេះ យើងជារដ្ឋមន្ត្រី និងតំណាងរដ្ឋាភិបាលនៃប្រទេសក្នុងមហាអនុតំបន់មេគង្គ សូមអះអាងនូវការប្តេជ្ញាចិត្តរបស់យើងចំពោះការសន្យាដែលមានចែងនៅក្នុងអនុស្សរណៈ**ខមមីត** ហើយសន្យាជាឱឡារិកថានឹងចាត់វិធានការឱ្យបានជាអតិបរមាតាមធនធានដែលមានស្រាប់ តាមប្រទេសនីមួយៗ ក៏ដូចជាការចាត់វិធានការរួមគ្នា និងតាមរយៈជំនួយ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីសម្រេចបានជាបន្តបន្ទាប់ និងសម្រេចបានពេញលេញចំពោះការប្តេជ្ញាចិត្ត ដែលបានទទួលស្គាល់នៅក្នុងអនុស្សរណៈ**ខមមីត** តាមមធ្យោបាយសមស្របនានា។ ជាមួយនឹងកិច្ចការទាំងនេះ យើងសូមលើកសរសើរដល់ការបន្តដំណើរការ**ខមមីត** តាមរយៈការបញ្ចប់ផែនការសកម្មភាពអនុតំបន់ទី១ និងការរៀបចំផែនការសកម្មភាពអនុតំបន់ទីពីរ ចាប់ពីឆ្នាំ ២០០៨

ដល់ ឆ្នាំ ២០១០។ យើងជម្រុញប្រព័ន្ធសហប្រជាជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន ទាំងស្រ្តី ទាំងបុរស ទាំងកុមារានិងកុមារី ក៏ដូចជាយុវជន និងយុវនារីទាំងអស់ ព្រមទាំងអង្គការក្រៅរដ្ឋាភិបាលផង ឱ្យធ្វើសហប្រតិបត្តិការជាមួយរដ្ឋាភិបាល ដោយគោរពស្វ័យភាពរបស់ខ្លួន និងគ្រប់ផ្នែកនៃសង្គមស៊ីវិលឱ្យប្តេជ្ញា ដោយខ្លួនឯងចូលរួមចំណែកជាមួយដំណើរការ**ខមមីត** ។

ធ្វើនៅ ប៉េកាំង ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧